# របាយការណ៍លទ្ធផលអង្កេតស្រាវជ្រាវ

# បញ្ជីបោះឆ្នោត និងការចុះឈ្មោះអ្នកបោះឆ្នោត



ខុមហ្វ្រែល COMFREL សហការជាមួយ

NICFEC

KHMER YOUTH ASSOCIATION

កក្កដា ឆ្នាំ ២០០៨

# ឧបត្ថម្ភដោយ

ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៤៥

ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ ទូរសារ ០២៣ ៨៨៣ ៧៥០

អ៊ីម៉េល: comfrel@comfrel.org, comfrel@online.com.kh

គេហទំព័រ: www.comfrel.org

របាយការណ៍លទ្ធផលអង្កេតស្រាវជ្រាវ

# បញ្ជីបោះឆ្នោត និងការចុះឈ្មោះអ្នកបោះឆ្នោត

កក្កដា ឆ្នាំ ២០០៩

# មាតិកា


បុព្វកថា ........ ១

១. សេចក្តីផ្តើម ........ ៣

២. គោលបំណងនៃគំរោង ........ ៥

៣. លទ្ធផលនៃគំរោង ........ ៦

៤. ដែនកំណត់នៃការអង្កេត និងបទពិសោធន៍រៀនសូត្រ ........ ៨

៥. សង្ខេបលទ្ធផលស្រាវជ្រាវ ........ ១០

៦. អនុសាសន៍ ........ ១២

ក. ការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ........ ១២

ខ. ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ........ ១៤

គ. ការចេញទម្រង់ ១០១៨ ........ ១៤

ឃ. ការកាត់បន្ថយការភ័យខ្លាច ........ ១៥

ង. ការកាត់បន្ថយភាពមិនប្រក្រតីទាក់ទងនឹងការទិញសន្លឹកឆ្នោត ........ ១៥

ច. ប្រព័ន្ធផ្សព្វផ្សាយ ........ ១៥

៧. វិភាគទិន្នន័យ ........ ១៦

៧.១ ការចូលរួមបោះឆ្នោតតាម ភេទ និងអាយុ ........ ១៦

៧.២ មូលហេតុដែលបណ្តាលអោយអ្នកបោះឆ្នោតមិនបានបោះឆ្នោត ........ ១៦

៧.៣ ករណីដែលមិនបានទៅការិយាល័យបោះឆ្នោត ........ ១៧

៧.៤ឧបសគ្គដែលកើតឡើងនៅការិយាល័យបោះឆ្នោត ........ ១៩

៧.៥ការប្រើប្រាស់ទំរង់ ១០១៨ ក្នុងការបោះឆ្នោតឆ្នាំ ២០០៨ ........ ២១

៧.៦ ប្រភេទឯកសារផ្សេងៗ (ក្រៅពីទម្រង់ ១០១៨) ដែលប្រើប្រាស់ក្នុងពេលបោះឆ្នោត ២០០៨ ........ ២១

៧.៧ មូលហេតុដែលតំរូវអោយមានការប្រើប្រាស់ទំរង់ ១០១៨ ........ ២២

៧.៨ ការស្ទង់មតិស្តីពីការប្រើប្រាស់ឯកសារបោះឆ្នោតនាពេលអនាគត....២៣

៧.៩ប័ណ្ណព័ត៌មានបោះឆ្នោត....២៤

៧.១០ ការចែកប័ណ្ណពត៌មានអ្នកបោះឆ្នោត....២៥

៧.១១ ការព្រួយបារម្ភរបស់អ្នកបោះឆ្នោត....២៦

៧.១២ យោបល់អ្នកបោះឆ្នោតចំពោះការផ្ទៀងផ្ទាត់ និងការចុះឈ្មោះបោះឆ្នោត....២៧

៧.១៣ ភាពមិនប្រក្រតីដែលកើតមានក្នុងកំឡុងពេលនៃការបោះឆ្នោត....២៨

៧.១៤ ការផ្ទៀងផ្ទាត់ព័ត៌មានអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០០៨....២៩

**៨. សេចក្តីសន្និដ្ឋាន....៣០**

**ឧបសម្ព័ន្ធ ១: វិធីសាស្ត្រនៃការស្រាវជ្រាវ....៣២**

**ឧបសម្ព័ន្ធ ២: កម្រងសំនួរសំរាប់ការអង្កេត....៣៨**

**ឧបសម្ព័ន្ធ ៣: ការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោតជាមួយបញ្ជីបោះឆ្នោតឆ្នាំ ២០០៩....៤១**

តារាងទី ១២: ការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោត (ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត) ក្នុងបញ្ជីបោះឆ្នោត ២០០៨ ៤១

តារាង ១៣: ការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោត (ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត អស័យដ្ឋាន) ក្នុងបញ្ជីបោះឆ្នោត ២០០៨....៤២

តារាង ១៤: ការផ្ទៀងផ្ទាត់ "ឈ្មោះ" អ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ២០០៨....៤៣

តារាង ១៥: ការផ្ទៀងផ្ទាត់ "ថ្ងៃខែឆ្នាំកំណើត" ក្នុងបញ្ជីបោះឆ្នោត ២០០៨....៤៤

តារាង ១៦: ការផ្ទៀងផ្ទាត់ "ភេទ" អ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ២០០៨....៤៥

តារាង ១៧: ការផ្ទៀងផ្ទាត់ "អស័យដ្ឋាន" (ឃុំ និងខេត្ត) អ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ២០០៨....៤៦

**ឧបសម្ព័ន្ធ ៣: ការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោតជាមួយបញ្ជីបោះឆ្នោតឆ្នាំ ២០០៩....៤៧**

**ឧបសម្ព័ន្ធ ៤: រូបភាពសកម្មភាពការងារ....៤៧**

# បុព្វកថា

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា (**ខុមហ្វ្រែល**) ធ្វើការដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការចូលរួមរបស់ប្រជាពលរដ្ឋ តាមគោលការណ៍កសាងសមត្ថភាពរបស់បណ្តាញទូទាំងប្រទេស និងសហប្រតិបត្តិការជាមួយអង្គការជាសមាជិក និងជាដៃគូ។ លទ្ធិប្រជាធិបតេយ្យមិនមែនត្រឹមតែការបោះឆ្នោតនោះទេ ក៏ប៉ុន្តែការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ជាលក្ខខណ្ឌចាំបាច់នៃលទ្ធិប្រជាធិបតេយ្យ ។

**ខុមហ្វ្រែល** (COMFREL) បន្តយ៉ាងខ្លាំងក្លាក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោតដ៏ត្រឹមត្រូវឥតក្លែងបន្លំ និងបែបប្រជាធិបតេយ្យ។

ការជួយឱ្យមានការកែទម្រង់នៃការបោះឆ្នោត, ខុមហ្វ្រែល និងភាគីពាក់ព័ន្ធការបោះឆ្នោតផ្សេងទៀតបានសហការរៀបចំធ្វើការអង្កេតស្រាវជ្រាវដើម្បីសិក្សាពីភាពមិនប្រក្រតីនៃការចុះឈ្មោះអ្នកបោះឆ្នោត បញ្ជីបោះឆ្នោត និងការចេញឯកសារអត្តសញ្ញាណទម្រង់ ១០១៨។ នៅពេលនោះ វាមិនទាន់មានការអង្កេតស្រាវជ្រាវដើម្បីដោះស្រាយបញ្ហាសំខាន់ៗមួយចំនួនទេដូចជា: តើអ្នកបោះឆ្នោតប៉ុន្មាននាក់មិនមានលទ្ធភាពបោះឆ្នោត? តើមានទម្រង់ ១០១៨ ប៉ុន្មានដែលបានចេញឱ្យប្រជាពលរដ្ឋ? តើការចុះឈ្មោះរបស់អ្នកបោះឆ្នោតមានកម្រិតភាពត្រឹមត្រូវប៉ុណ្ណា?

នៅក្នុងការសិក្សាស្រាវជ្រាវនេះ **ខុមហ្វ្រែល** (COMFREL) មានមោទនភាព និងអំណរគុណដ៏ជ្រាវជ្រៅបំផុតដល់គ្រូបង្គោល អ្នកសង្កេតការណ៍ និងអង្គការមិនមែនរដ្ឋាភិបាលដៃគូមួយចំនួនដូចជា: គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (និកហ្វិច/NICFEC) បុគ្គលិកតាមខេត្តរបស់សាមាគមអាដហុក (ADHOC) មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (ភីឌីភី/PDP) សមាគមយុវជនខ្មែរ (ឃេ វ៉ាយ អេ/KYA) និងវេទិកានៃប្រជាពលរដ្ឋស្តីពីកម្ពុជា, ប្រទេសជប៉ុន (PEFOC,J) ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងប្រតិបត្តិការអង្កេតស្រាវជ្រាវក្នុងកំឡុងពេល ពីខែ កុម្ភៈ ដល់ខែ មិថុនា ឆ្នាំ ២០០៩ ហើយដែលធ្វើអោយការស្រាវជ្រាវនេះបានសំរេចជាស្ថាពរ។

**ខុមហ្វ្រែល** ក៏សូមថ្លែងអំណរគុណដ៏ជ្រាវជ្រៅនូវការផ្តល់សហប្រតិបត្តិការពីក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) គណបក្សនយោបាយសំខាន់ៗមួយចំនួន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ ។

**ខុមហ្វ្រែល** ក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ម្ចាស់ជំនួយដូចជា កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP), Forum Syd, NPA (Norwegian People’s Aid) និងស្ថានទូតអង់គ្លេស ។

ជាពិសេស សូមថ្លែងអំណរគុណផងដែរដល់ក្រុមការងាររបស់ **ខុមហ្វ្រែល** ដែលមានរាយនាម ដូចជា : លោក កន សាវាង្ស លោក សុខ ពិទូរ្យ លោក គីម ឈន លោក កុយ ច័ន្ទដារិទ្ធ អ្នកស្រី ម៉ៅ ផល្លី កញ្ញា សៀង ដាលីយ៉ា លោក ប្លុង ហឿត លោក សិន ទិត្យសីហា លោក តាំង សុខា និង កញ្ញា មឿន សុខមុនី ក្រោមការដឹកនាំរបស់លោក គល់ បញ្ញា នាយកប្រតិបត្តិ **ខុមហ្វ្រែល** ។ សូមថ្លែងអំណរគុណផងដែរដល់ លោក មាក កាមេរ៉ាន ដែលបានសិក្សាបង្កើតបច្ចេកទេស និងវិធីសាស្ត្រនៃការអង្កេត ព្រមទាំងលោកស្រី Roo Griffiths ដែលបានចូលរួមផ្តល់យោបល់ ពិនិត្យ កែសំរួល និងផ្ទៀងផ្ទាត់របាយការណ៍នេះ ។

របាយការណ៍នេះ បង្ហាញលទ្ធផលនៃការអង្កេតដែលទាក់ទិនទៅនឹងអ្នកបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត បញ្ជីបោះឆ្នោត ទំរង់១០១៨ និងការផ្ទៀងផ្ទាត់ព័ត៌មានអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០០៨ ។

# បញ្ជីឈ្មោះអ្នកបោះឆ្នោត និង ការចុះឈ្មោះបោះឆ្នោត

## ១. សេចក្តីផ្តើម

នៅក្នុងកំឡុងពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ ការចុះឈ្មោះអ្នកបោះឆ្នោត និងការសំអាតបញ្ជីបោះឆ្នោតមានភាពមិនប្រក្រតីមួយចំនួន បើទោះបីមានកិច្ចប្រឹងប្រែងធ្វើឱ្យមានដំណើរការនេះមានភាពប្រសើរឡើងក៏ដោយ។ ចាប់តាំងពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៧មក ភាពជឿជាក់របស់ភាគីធ្វើការពាក់ព័ន្ធការបោះឆ្នោតទៅលើបញ្ជីបោះឆ្នោតមានការថយចុះ។

នៅក្នុងប្រព័ន្ធចុះឈ្មោះបច្ចុប្បន្ន (ចាប់តាំងពីឆ្នាំ ២០០៣មក) មិនមានចេញប័ណ្ណបោះឆ្នោតដល់អ្នកបោះឆ្នោតទេ ហើយការចុះឈ្មោះអ្នកបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតត្រូវអនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ជ.ប រៀងរាល់ឆ្នាំ។ នៅក្នុងឆ្នាំ ២០០៤ គ.ជ.ប បានរៀបចំថវិកា ៨០០.០០០ ដុល្លារអាមេរិកសម្រាប់ការចុះឈ្មោះ។ នេះមានន័យថាតាមប្រព័ន្ធបច្ចុប្បន្ន ក្នុងការបោះឆ្នោតមួយដង (៥ ឆ្នាំម្តង) ការប៉ាន់ស្មានការចំណាយគឺប្រមាណ ៤លានដុល្លារ ដោយមិនរាប់បញ្ចូលការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតដែលត្រូវចំណាយប្រមាណពី ២០០.០០០ដុល្លារ ទៅ៣០០.០០០ដុល្លារនោះទេ។ នៅក្នុងឆ្នាំ ២០០២ ដែលប្រើប្រាស់ប្រព័ន្ធចុះឈ្មោះចាស់ ការចុះឈ្មោះបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតគឺធ្វើឡើងដោយ គ.ជ.ប។ ការចំណាយសម្រាប់ការចុះឈ្មោះសម្រាប់ការបោះឆ្នោតឃុំ សង្កាត់ រួមមានទាំងការធ្វើប័ណ្ណបោះឆ្នោតដែលមានបិទរូបថតរបស់អ្នកបោះឆ្នោតផងដែរ។ ការចំណាយសរុបសម្រាប់ប្រតិបត្តិការចុះឈ្មោះអ្នកបោះឆ្នោតគឺអស់៤,៩ លានដុល្លារក្នុងឆ្នាំ ២០០២ ហើយថវិកានេះត្រូវបានបញ្ចូលទៅក្នុងថវិកាសម្រាប់ការរៀបចំការបោះឆ្នោតឃុំ សង្កាត់ ឆ្នាំ ២០០២។

ដូចនេះ ប្រព័ន្ធចុះឈ្មោះបច្ចុប្បន្នគឺចំណេញបាន ០,៩ លានដុល្លា ក្នុងការបោះឆ្នោតម្តង (៥ឆ្នាំ)។ ទោះបីយ៉ាងណាតាមការអង្កេតទៅលើការបោះឆ្នោតឆ្នាំ ១៩៩៨ និងឆ្នាំ ២០០២ ការចុះឈ្មោះអ្នកបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតដោយ គ.ជ.ប គឺមានប្រសិទ្ធភាព និងគុណភាពល្អជាងប្រព័ន្ធបច្ចុប្បន្ន។ ក្នុងពេលនោះ វាមិនមានបញ្ហាធ្ងន់ធ្ងរ ហើយគ្មានបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោត ឬអ្នកបោះឆ្នោតលំបាកក្នុងការបោះឆ្នោតនោះទេ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានធ្វើការប៉ាន់ស្មានប្រចាំឆ្នាំជាមុន មុននឹងមានការចុះឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតដែលមិនទាន់បានចុះឈ្មោះ។ ទាក់ទិនទៅនឹងការប៉ាន់ស្មាន នៅក្នុងឆ្នាំ ២០០៦ គ.ជ.ប បានប៉ាន់ស្មាន ថាមានអ្នកមានសិទ្ធិបោះឆ្នោតប្រមាណពី ៦០០.០០០ ទៅ ៧០០.០០០ នាក់មិនទាន់បានចុះឈ្មោះ។ នៅក្នុងពេលនោះ ផងដែរ វិទ្យាស្ថានជាតិស្ថិតិ (NIS) បានបង្ហាញថា ជារៀងរាល់ឆ្នាំ មានអ្នកមានសិទ្ធិបោះឆ្នោតប្រមាណ ពី ៣០០.០០០ នាក់ ទៅ ៤០០.០០០ នាក់ ដែលទើបតែគ្រប់អាយុ ១៨ឆ្នាំ ។ ក្រោយពីការចុះឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០០៦ និង ២០០៧ ការវាយតំលៃរបស់ គ.ជ.ប អាចឱ្យគេរកឃើញថា ភាគរយនៃអ្នកបោះឆ្នោតចុះឈ្មោះថ្មីមាន ១៣០% សំរាប់ឆ្នាំ២០០៧ និង

២០០% សំរាប់ឆ្នាំ២០០៦ ឬសម្រាប់ឆ្នាំ២០០៦ មានអ្នកចុះឈ្មោះថ្មី ៣០០% បើធៀបនឹងទិន្នន័យរបស់វិទ្យាស្ថាន ជាតិស្ថិតិ។ នៅចន្លោះខែតុលា និងខែធ្នូ ឆ្នាំ២០០៨ ការចុះឈ្មោះបោះឆ្នោតបានប្រព្រឹត្តទៅ ហើយនៅឆ្នាំ២០០៨ បញ្ជីបោះឆ្នោតបានរៀបចំជាស្រេច។ បញ្ហាដែលចោទសួរថា តើបញ្ជីបោះឆ្នោតឆ្នាំ ២០០៨ មានភាពសុក្រឹតត្រឹមកំរិតណា? នៅក្នុងកំឡុងពេលបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រនៅថ្ងៃទី ២៧ កក្កដា ២០០៨ អង្គការ **ខុមហ្វ្រែល** ព្រមទាំងអង្គការអង្កេតការបោះឆ្នោតផ្សេងទៀត បានកត់សំគាល់ឃើញថា ដំណើរការនៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យ រាប់សន្លឹកឆ្នោតប្រព្រឹត្តទៅមានលក្ខណៈត្រឹមត្រូវតាមបច្ចេកទេស បទបញ្ជា និងនីតិវិធី ក៏ប៉ុន្តែវាមានភាពមិនប្រក្រតីធ្ងន់ធ្ងរ មួយចំនួនដែលធ្វើអោយប្រជាជនបាត់បង់សិទ្ធិបោះឆ្នោតនិងបញ្ហានៃការចេញទំរង់ ១០១៨។

ទាក់ទិនទៅនឹងបញ្ហានេះ មានអ្នកបោះឆ្នោតមួយចំនួនពុំបានបោះឆ្នោតដោយសារមានបញ្ហាកើតឡើងនៅការិយាល័យបោះឆ្នោតដែលក្នុងនោះមានៈ ១) អ្នកបោះឆ្នោតពុំអាចរកឃើញឈ្មោះរបស់ខ្លួននៅក្នុងបញ្ជីបោះឆ្នោត ២) អ្នកបោះឆ្នោតពុំដឹងអំពីការិយាល័យបោះឆ្នោតរបស់ខ្លួនដែលត្រូវទៅ (ពុំបានទទួលប័ណ្ណព័តិមានបោះឆ្នោត ឬក៏ពុំដឹងពី ការផ្លាស់ប្តូរលេខ/ទីតាំងការិយាល័យបោះឆ្នោតរបស់ខ្លួន) ៣) អ្នកបោះឆ្នោតមានការភាន់ច្រឡំក្នុងការប្រើប្រាស់ប័ណ្ណព័តិមានបោះឆ្នោតសំរាប់ការចូលរួមការបោះឆ្នោត។

ស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោតភាគច្រើន ត្រូវបានគេសង្កេតឃើញថា ភាគរយនៃអ្នកបានបោះឆ្នោត ធៀបនឹងអ្នកមានសិទ្ធិ បោះឆ្នោតទាំងអស់មានការថយចុះ ហើយក៏មានការថយចុះខ្លាំងនៅតំបន់មួយចំនួន (មានការថយចុះ ២០% បើធៀបទៅនឹង ការបោះឆ្នោតឆ្នាំ ២០០៣)។ របាយការណ៍លទ្ធផលបោះឆ្នោតរបស់ គ.ជ.ប បានបង្ហាញអោយឃើញថា ៧៥%នៃប្រជាពលរដ្ឋ ចំនួនប្រមាណ៨,១២ លាននាក់ ក្នុងបញ្ជីបោះឆ្នោតបានបោះឆ្នោត និងមាន២៥% ស្មើនឹងប្រមាណ ២លាននាក់ពុំបាន បោះឆ្នោតទេ។ នេះក៏អាចជាសញ្ញាមួយដែលបានបង្ហាញអោយឃើញថា ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត បានធ្វើអោយ ប៉ះពាល់ទៅលើសិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋ។

ទន្ទឹមនឹងនេះ អង្គការសង្កេតការណ៍បោះឆ្នោត និងគណបក្សនយោបាយមួយចំនួនមានការខ្វល់ខ្វាយទៅលើភាពមិនប្រក្រតីទាក់ទិនទៅនឹងការចេញទំរង់ ១០១៨។ នៅក្នុងករណីនេះដែរ គ.ជ.ប មិនមានលទ្ធភាពក្នុងការបង្ហាញពីចំនួន ទំរង់ ១០១៨ ដែលបានចេញទេ។ ទំរង់ ១០១៨ គឺជាឯកសារ១ ក្នុងចំណោមឯកសារទាំង ១១ ដែលអនុញ្ញាតអោយអ្នកបោះឆ្នោតប្រើកំណត់អត្តសញ្ញាណរបស់ខ្លួនសំរាប់ ការចូលរួមការបោះឆ្នោត។ ទំរង់នេះត្រូវបានចេញអោយអ្នកបោះឆ្នោតណាដែលពុំមានឯកសារបញ្ជាក់អត្តសញ្ញាណ។ ដើម្បីផ្តល់ ទំរង់ ១០១៨ អោយអ្នកបោះឆ្នោតណាម្នាក់ អ្នកបោះឆ្នោតនោះត្រូវនាំមកជាមួយនូវអ្នកមានសិទ្ធិបោះឆ្នោតចំនួន ពីរនាក់ ដែលរស់នៅក្នុងឃុំជាមួយគ្នាដើម្បីបញ្ជាក់អត្តសញ្ញាណ អាយុ និង ទីកន្លែងរស់នៅរបស់បុគ្គលនោះ ។

របាយការណ៍ចុងក្រោយរបស់សហគមន៍ អឺរ៉ុប នៅក្នុងបេសកកម្មអង្កេតការបោះឆ្នោតនៅប្រទេសកម្ពុជា (European Union Election Observation Mission) ចេញផ្សាយខែតុលា ឆ្នាំ២០០៨ បានផ្តល់យោបល់ជាសារវន្តថា ការប្រើប្រាស់ទំរង់ ១០១៨ "ត្រូវតែលុបចោលសម្រាប់ការបោះឆ្នោតនាពេលអនាគត ប្រវត្តិនៃឯកសារអត្តសញ្ញាណដែលប្រើប្រាស់ដោយអ្នកបោះឆ្នោតត្រូវរក្សាទុកដើម្បីធានា និងធ្វើជាព័ត៌មានសម្រាប់កែលំអថែមទៀតទៅលើក្របខណ្ឌបោះឆ្នោតនៅកម្ពុជា។ ឯកសារទាំងនេះនឹងប្រើជាឯកសារពិគ្រោះយោបល់សំរាប់សំរួល និងកែលំអដំណើរការនៃការចុះឈ្មោះបោះឆ្នោត និងការចូលរួមបន្ថែមរបស់មន្ត្រី គ.ជ.ប ក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតប្រចាំឆ្នាំ។

ទោះបីជាអង្គការ**ខុមហ្វ្រែល** (COMFREL) និងភាគីពាក់ព័ន្ធការបោះឆ្នោតផ្សេងទៀតបានអង្កេត និងលាតត្រដាងនូវភាពមិនប្រក្រតី និងតំរូវការចាំបាច់ក្នុងការកែលំអវិធីសាស្ត្រនៃការចុះឈ្មោះ និងបញ្ជីបោះឆ្នោតយ៉ាងណាក៏ដោយ ក៏ពុំទាន់មានការឆ្លើយតបទៅនឹងសំនួរសំខាន់ៗខ្លះដូចជា: តើមានអ្នកបោះឆ្នោតប៉ុន្មាននាក់ ឬប៉ុន្មានភាគរយ ដែលមិនបានបោះឆ្នោត? ហេតុអ្វី? តើមានទំរង់ ១០១៨ ចំនួនប៉ុន្មានដែលបានចេញ? តើភាពត្រឹមត្រូវក្នុងការចុះឈ្មោះ ឬបញ្ជីបោះឆ្នោតមានត្រឹមកំរិតណា?

## ២. គោលបំណងនៃគំរោង

ដើម្បីគាំទ្រដល់ការកែលំអប្រព័ន្ធនៃការចុះឈ្មោះបោះឆ្នោត ការបង្កើតបញ្ជីបោះឆ្នោត ការចេញទំរង់អត្តសញ្ញាណ និងបញ្ហារបស់អ្នកបោះឆ្នោត **ខុមហ្វ្រែល** បានធ្វើការអង្កេតស្រាវជ្រាវទៅលើអ្នកមានសិទ្ធិបោះឆ្នោតមួយចំនួនដែលពុំបានបោះឆ្នោត ការចេញទំរង់ ១០១៨ និងបញ្ជីបោះឆ្នោតឆ្នាំ២០០៨។ ការសិក្សាស្រាវជ្រាវនេះ មានគោលដៅជួយជំរុញការចូលរួមបោះឆ្នោតរបស់ ប្រជាពលរដ្ឋ និងជួយការពារសិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋកម្ពុជា។

គោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីកំណត់បញ្ហានៃអ្នកបោះឆ្នោត វិភាគទៅលើមធ្យោបាយនៃការចេញទំរង់ ១០១៨ និងការ ចុះឈ្មោះអ្នកបោះឆ្នោត ព្រមទាំងផ្ទៀងផ្ទាត់នូវភាពសុក្រឹតនៃបញ្ជីបោះឆ្នោតឆ្នាំ២០០៨ ដើម្បីផ្តល់ព័ត៌មាននេះដល់ គ.ជ.ប គណបក្សនយោបាយ ឬភាគីពាក់ព័ន្ធនានា ព្រមទាំងផ្តល់អនុសាសន៍ដើម្បីកែលំអប្រព័ន្ធបច្ចុប្បន្ន ឬក៏ការបង្កើតប្រព័ន្ធថ្មីសំរាប់ ការចុះឈ្មោះអ្នកបោះឆ្នោត និងការចេញទំរង់អត្តសញ្ញាណ ។

## ៣. លទ្ធផលនៃគំរោង

ការស្រាវជ្រាវ ត្រូវបានធ្វើឡើងនៅថ្នាក់ភូមិក្នុង ២៤ ខេត្ត ក្រុងទូទាំងប្រទេស។ ការស្រាវជ្រាវបានកំណត់ យកកំហុសធំបំផុតក្នុងការវាយតំលៃ (Margin of error) +/- ៥% និងកំរិតជឿជាក់ (Confidence level) ៩៥%។ សកម្មភាពស្រាវជ្រាវនេះត្រូវធ្វើឡើងជា ២ ដំណាក់កាលៈ ទី១ ធ្វើឡើងនៅក្នុង ១៤ ខេត្ត ក្រុង ពីថ្ងៃទី ២៣ កុម្ភៈ ដល់ ៣០ មេសា, និងដំណាក់កាលទី ២ នៅក្នុងខេត្ត ក្រុងចំនួន ១០ ពីថ្ងៃទ ១ មេសា ដល់ថ្ងៃទី៣០ មិថុនា ២០០៩។

### លទ្ធផលទី ១

វិធីសាស្ត្រ និងសកម្មភាពនៃការស្រាវជ្រាវ ត្រូវបានរៀបចំឡើងដោយទីប្រឹក្សាជំនាញ និងក្រុមការងារ របស់ **ខុមហ្វ្រែល**។ ទំរង់សំនួរបានរៀបចំឡើង ដោយឆ្លងកាត់ការពិភាក្សាជាមួយអ្នកជំនាញរបស់វេទិកានៃប្រជាពលរដ្ឋកម្ពុជា, ប្រទេសជប៉ុន (PEFOC-J) និងសេវាកម្មអន្តរជាតិសម្រាប់កំណែទម្រង់ប្រព័ន្ធបោះឆ្នោត (ERIS) និងភាគីពាក់ព័ន្ធមួយចំនួនក្នុងនោះមាន គ.ជ.ប និងក្រសួងមហាផ្ទៃ និងគណបក្សនយោបាយសំខាន់ៗមួយចំនួនដូចជា គណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី គណបក្សនរោត្តមរណឫទ្ធិ និងគណបក្សហ៊្វុនស៊ិនប៉ិច។

វិធីសាស្ត្រ “Stratified sampling” ត្រូវបានប្រើសំរាប់កំណត់យកការិយាល័យបោះឆ្នោតក្នុងឃុំ និងស្រុកទូទាំងប្រទេស។ វិធីសាស្ត្រ “Systematic sampling” បានប្រើសំរាប់ជ្រើសរើសយកគ្រួសារគោលដៅនីមួយៗ ហើយសមាជិកនៅក្នុងគ្រួសារនីមួយៗត្រូវបានជ្រើសរើសដោយប្រើប្រព័ន្ធចៃដន្យ (Simple Random Sampling) សំរាប់ការធ្វើបទសម្ភាសន៍ (សូមមើលឧបសម្ព័ន្ធទី១)។

ដោយមានសហប្រតិបត្តិការជាមួយអង្គការដៃគូជាច្រើន ដូចជា និកហ្វិច សមាគមយុវជនខ្មែរ មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីការអភិវឌ្ឍន៍ និងសន្តិភាព អង្គការ **ខុមហ្វ្រែល** បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយ សមាជិករបស់ គ.ជ.ប រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងថ្នាក់ដឹកនាំគណបក្សនយោបាយមួយចំនួនដូចជា គណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សនរោត្តមរណឫទ្ធិ និងគណបក្សហ៊្វុនស៊ិនប៉ិច ដែលក្នុងចំណោមអ្នកទាំងនោះ មាន ៨៦% (៦ លើ ៧ សំលេង) បានគាំទ្រលើការអង្កេត និងស្រាវជ្រាវរបស់ **ខុមហ្វ្រែល** ។ នៅក្នុងពេលនោះ គ.ជ.ប ស្ថិតនៅក្នុងលក្ខណៈអព្យាក្រឹត ដោយពុំបានប្រឆាំង ឬក៏គាំទ្រការអង្កេតស្រាវជ្រាវនេះទេ។ ចំណែកឯក្រសួងមហាផ្ទៃបានចេញលិខិតផ្លូវការដើម្បីជួយសំរួលឱ្យមានកិច្ចសហប្រតិបត្តិការរវាងអ្នកចុះសម្ភាសន៍ និងអាជ្ញាធរមូលដ្ឋាន។

### លទ្ធផលទី ២

នៅក្នុងការស្រាវជ្រាវនេះ យើងមានអ្នកអង្កេតចុះតាមមូលដ្ឋានចំនួន៣២១នាក់ ដែលសុទ្ធតែបានឆ្លងកាត់ការបង្រៀនពីបច្ចេកទេសសម្ភាសន៍ ហើយអ្នកទាំងនោះបានចុះទៅសម្ភាសន៍អ្នកបោះឆ្នោតចំនួន ៨.៦៧៨ នាក់ក្នុង ២៤ ខេត្ត/ក្រុង ទូទាំងប្រទេសទៅតាមទីតាំងការិយាល័យបោះឆ្នោតសំណាកចំនួន ៧៧០ ការិយាល័យ ។

គ្រូបង្គោលចំនួន ១៥ នាក់ និងក្រុមការងាររបស់គណៈកម្មាធិការខុមហ្វ្រែល (Comfrel) និកហ្វិច (Nicfec) ឃេវ៉ាយអេ (KYA) និងភីឌីភី (PDP) បានឆ្លងកាត់ការបង្ហាញ និងសិក្សាជាពិសេសជាមួយអ្នកឯកទេសផ្នែកស្រាវជ្រាវ និងមន្ត្រីជំនាញរបស់មន្ត្រី ខុមហ្វ្រែល។ គ្រូបង្គោលទាំង ១៥នាក់ បានចុះទៅបង្រៀនអ្នកសង្កេតការណ៍ដែលបានរៀបចំ ចំនួន ៩វគ្គ ហើយក្នុង ០១វគ្គ មានរយៈពេល ០២ថ្ងៃ សំរាប់អ្នកសង្កេតការណ៍មកពី ២៤ខេត្ត/ក្រុង។ អ្នកសង្កេតការណ៍ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលមានចំនួន ៣២១នាក់ ក្នុងនោះមាន ២២% ជាស្ត្រី បានចូលនៅក្នុងខែ កុម្ភៈ និងខែ មេសា ឆ្នាំ ២០០៩។

អ្នកសង្កេតការណ៍តាមមូលដ្ឋានចំនួន ៣២១ នាក់ បានធ្វើបទសម្ភាសន៍ទៅលើអ្នកមានសិទ្ធិបោះឆ្នោត ចំនួន ៨.៦៧៨ នាក់ នៅក្នុងកំឡុងពេលពីខែ មីនា ដល់ខែ ឧសភា ឆ្នាំ២០០៩។ ក្នុង**តារាងទី១** បានបង្ហាញពីចំនួនអ្នកត្រូវបានសម្ភាស ដែលបែងចែកទៅតាម **ភេទ និងអាយុ**។

**តារាងទី ១: ចំនួនអ្នកផ្តល់បទសម្ភាសន៍តាម ភេទ និងអាយុ**

| | | |
|---|---|---|
| **ចំនួនអ្នកផ្តល់បទសម្ភាសន៍មាន ចំនួន ៨.៦៧៨ នាក់ (៧.៩៥៩ បានបោះឆ្នោតក្នុងឆ្នាំ ២០០៨)** | ប្រុស | **៦២,៣៣%** |
| | ស្រី | **៣៧,៦៧%** |
| | **អាយុ (១៨ - ៣០)** | **២៨,២%** |

អ្នកត្រួតពិនិត្យថ្នាក់ខេត្តចំនួន ២៤ នាក់ និងគ្រូបង្គោល ៨ នាក់ ត្រូវបានកំណត់អោយចុះត្រួតពិនិត្យ ២២ ទីតាំង ដើម្បីធ្វើការត្រួតពិនិត្យផ្ទាល់ចំពោះក្រុមការងារ និងជួយប្រធានក្រុមនៅមូលដ្ឋាន ពេលមានបញ្ហាដោយប្រការណាមួយនៅក្នុងកំឡុងពេលនៃការចុះសម្ភាសរបស់អ្នកចុះសម្ភាសន៍។

### លទ្ធផលទី ៣

*របាយការណ៍ចុងក្រោយ និងអនុសាសន៍នៃការស្រាវជ្រាវនេះនឹងត្រូវបញ្ជូនទៅសភាជាតិ សមាជិកសភា គណបក្សនយោបាយសំខាន់ៗមួយចំនួន ក្រសួងមហាផ្ទៃ គ.ជ.ប ម្ចាស់ជំនួយ និងប្រព័ន្ធផ្សព្វផ្សាយ។*

ទំរង់សំណួរអង្កេតដែលត្រូវបានបំពេញមានចំនួន ៨.៦៧៨ ទំរង់ ហើយត្រូវបានត្រួតពិនិត្យដោយក្រុមការងារពិសេស និង គ្រូបង្គោលដើម្បីឱ្យប្រាកដថា ជាចម្លើយត្រឹមត្រូវតាមបច្ចេកទេស។

ទិន្នន័យត្រូវបានបញ្ចូល ក្នុងនោះ ៩៩.៨% នៃទិន្នន័យសរុប ត្រូវបានបញ្ចូលនៅក្នុងកំឡុងពេលពីខែ មីនា ដល់ខែ ឧសភា ឆ្នាំ២០០៩ ដោយអ្នកវាយបញ្ចូល ចំនួន ១០ នាក់ ទៅក្នុងម៉ាស៊ីន កុំព្យូទ័រ (Database) ហើយត្រូវបានវិភាគ ដោយអ្នកជំនាញឯកទេស។

មន្ត្រីគំរោងខុមហ្វ្រែល ក្រុមការងារពិសេស និងទីប្រឹក្សាជំនាញ បានរៀបចំលទ្ធផល អនុសាសន៍ នាដើមខែ មិថុនា ឆ្នាំ២០០៩។ ចន្លោះពីពាក់កណ្តាលខែ ដល់ ចុងខែមិថុនា ២០០៩ លទ្ធផលស្រាវជ្រាវ និងអនុសាសន៍ព្រាងត្រូវបានយកមក ពិភាក្សាក្នុងកិច្ចប្រជុំរវាងក្រុមការងារពិសេស សមាជិកគណៈកម្មាធិការនាយកខុមហ្វ្រែល អង្គការដៃគូ និងម្ចាស់ជំនួយ។ របាយការណ៍ និងអនុសាសន៍ព្រាងក៏ត្រូវបានបង្ហាញ និងពិភាក្សាជាមួយ គ.ជ.ប (សមាជិក គ.ជ.ប និងអគ្គលេខាធិការ) និងក្រសួងមហាផ្ទៃ (ដឹកនាំដោយអគ្គនាយករងនៃអគ្គនាយកមូលដ្ឋាននៃក្រសួងមហាផ្ទៃ)។ គ.ជ.ប មានការចាប់អារម្មណ៍ទៅ នឹងការរកឃើញខ្លះៗ ហើយបានផ្តល់ព័ត៌មានបន្ថែមទាក់ទងទៅលទ្ធផល និងអនុសាសន៍។ តំណាង គ.ជ.ប និងក្រសួងមហាផ្ទៃ បានថ្លែងថា ពួកខ្លួននឹងរាយការណ៍ពីកិច្ចពិភាក្សាទៅថ្នាក់លើរបស់ខ្លួន។ ភ្នាក់ងារផ្តល់ជំនួយមួយចំនួនបានផ្តល់យោបល់ថា អនុសាសន៍គួរតែច្បាស់លាស់ និងឆ្លើយតបទៅនឹងលទ្ធផល។ របាយការណ៍អង្កេតស្រាវជ្រាវនេះត្រូវបានបញ្ចប់នៅពាក់កណ្តាល់ ខែកក្កដា ឆ្នាំ២០០៩ ហើយសន្និសីទកាសែតនឹងធ្វើឡើងនៅចុងខែកក្កដា ២០០៩។

របាយការណ៍ចុងក្រោយនឹងអនុសាសន៍នឹងត្រូវផ្តល់ជូនរដ្ឋសភា សមាជិករដ្ឋសភា ក្រសួងមហាផ្ទៃ គណបក្ស នយោបាយសំខាន់ៗ ម្ចាស់ជំនួយ និងប្រព័ន្ធផ្សព្វផ្សាយ។

លទ្ធផលនៃការអង្កេត និងអនុសាសន៍នឹងត្រូវបង្ហាញ ឬពិភាក្សានៅក្នុងសិក្ខាសាលាក្នុងខែសីហា ២០០៩ ស្តីពីកំណែ ទំរង់ការបោះឆ្នោតដែលនឹងរៀបចំដោយវិទ្យាស្ថានជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ (NDI) និងអ្នកជំនាញមកពីសង្គមស៊ីវិល។ លទ្ធផល និងរបាយការណ៍ ក៏នឹងត្រូវយកមកបង្ហាញ និងពិភាក្សាក្នុងសន្និសីទជាតិស្តីពី ការចុះឆ្មោះអ្នកបោះឆ្នោតដែលរៀបចំ ឡើងដោយទីប្រឹក្សារបស់សហគមន៍អឺរ៉ុប សម្រាប់ គ.ជ.ប។

## ៤. ចំណុចខ្វះខាត និងការដកពិសោធន៍មេរៀនពីការងារអង្កេត

- មានការិយាល័យបោះឆ្នោត (ភូមិ ) សំណាកចំនួន ៣ ក្នុងខេត្តកណ្តាលដែលអ្នកចុះអង្កេតជួបប្រទះបញ្ហាក្នុងការ ធ្វើបទសម្ភាសន៍ទៅលើប្រជាពលរដ្ឋចំនួន ១៤ នាក់ ដោយមូលហេតុថា អាជ្ញាធរដែនដីមិនអនុញ្ញាតអោយចូលទៅ ធ្វើបទសម្ភាសន៍។ នៅក្នុងករណីនេះ កំរងសំនួរត្រូវបានបំពេញតាមក្រោយ ហើយត្រូវបានផ្ញើមកយឺត តែទោះ បីយ៉ាងណាក៏ដោយ ក៏ពុំមានផលប៉ះពាល់ដល់លទ្ធផលក្នុងការស្រាវជ្រាវដែរ។

- អ្នកផ្តល់បទសម្ភាសន៍មួយចំនួន ដែលយើងជ្រើសរើសបានធ្វើចំណាកស្រុកទៅបំពេញការងារនៅឯខាងក្រៅផ្ទះ ក្នុង ករណីអ្នកមានសិទ្ធិបោះឆ្នោតមិននៅ យើងជ្រើសរើសយកអ្នកបន្ទាប់នៅក្នុងគ្រួសារនេះដើម្បីសម្ភាសន៍។

- គួរមានពេលច្រើនជាងនេះក្នុងការអនុវត្តសកម្មភាពនីមួយៗនៃការងារគំរោងនេះ។ យើងមានតែរយៈខ្លីប៉ុណ្ណោះសំរាប់ការជ្រើសរើសអ្នកប្រមូលព័តិមាន អ្នកស្ម័គ្រចិត្ត ហើយចំនួនតិចតួចក្នុងចំណោមអ្នកទាំងនោះមិនមានការយល់ដឹងគ្រប់គ្រាន់នឹងការងារនេះ (មានចំណេះដឹងតិចតួច នៅក្មេងពេក ពុំមានបទពិសោធន៍ ពុំមានពេលគ្រប់គ្រាន់ក្នុងការប្រតិបត្តិការងារ ឬពិបាកនឹងទាក់ទង)។

- ទំរង់សំនួរ និងឯកសារត្រូវតែពិភាក្សាឱ្យរួចរាល់យ៉ាងតិចមួយសប្តាហ៍មុននឹងចាប់ផ្តើមបើកវគ្គ និងបង្រៀនដល់គ្រូបង្គោល។ បើសិនការពិភាក្សាមានរយៈពេលខ្លីពេក នោះឯកសារពុំបានរៀបចំឱ្យបានល្អ ហើយគ្រូបង្គោលនឹងពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យ និងពន្យល់ដល់សិក្ខាកាមចូលរួមក្នុងវគ្គបណ្តុះបណ្តាល។ មានឯកសារខ្លះត្រូវបានទុកខុសកញ្ចប់ ហើយបែងចែកខុសទីតាំងត្រូវបង្រៀន និងមានខ្លះទៀតបាត់តែម្តង ដោយពេលវេលាខ្លី ។ល។

- ទំរង់សំនួរសំរាប់ការអង្កេតត្រូវបានបែងចែកជាពីរផ្នែកយ៉ាងច្បាស់លាស់។ នៅក្នុងផ្នែកទីមួយនៃទំរងសំនួរបង្ហាញអំពីការស្រាវជ្រាវទាក់ទិន្ននឹងអ្នកបោះឆ្នោត ក្នុងនោះមានសំណួរអង្កេតទៅលើការបោះឆ្នោតឆ្នាំ ២០០៨ និងសំនួរអង្កេតទៅលើការបោះឆ្នោតឆ្នាំ២០០៧ផង ដោយមានសំណួរច្របូកច្របល់គ្នា។ បញ្ហានេះ គឺធ្វើអោយមានការភាន់ច្រឡំដល់អ្នកធ្វើបទសម្ភាសន៍ក្នុងការសួរទៅប្រជាពលរដ្ឋ។

- ក្រសួងមហាផ្ទៃបានចេញលិខិតជូនដំណឹងដល់អាជ្ញាធរដែនដីស្តីអំពី សកម្មភាពអង្កេតរបស់ **ខុមហ្វ្រែល**។ បើសិនជាគ្មានលិខិតនេះទេនោះ ការប្រមូលព័តិមានមិនបានប្រព្រឹត្តទៅដោយសេរីនោះទេ ហើយអ្នកប្រមូលព័តិមាន នឹងត្រូវជួបប្រទះនូវបញ្ហាពីសំណាក់អាជ្ញាធរមូលដ្ឋាន។ នៅក្នុងឃុំខ្លះនៃខេត្តមួយចំនួន ទោះបីជាបង្ហាញលិខិតនេះ ក៏ដោយក៏មេភូមិមិនអនុញ្ញាតឱ្យចូលធ្វើបទសម្ភាសដែរ បើសិនជាគ្មានការអនុញ្ញាតពីរដ្ឋអំណាចឃុំ ស្រុក ឬខេត្ត ទេនោះ។ នៅក្នុងករណីនេះ លេខាធិការខេត្តរបស់**ខុមហ្វ្រែល** បានសរសេរលិខិតសូមការអនុញ្ញាតពីរដ្ឋអំណាច ថ្នាក់ខេត្ត។ ដើម្បីទទួលបានការចុះហត្ថលេខានេះ យើងត្រូវការរង់ចាំ និងចំណាយពេលយ៉ាងយូរដើម្បីបានធ្វើ បទសម្ភាសន៍។ នៅតាមភូមិមួយចំនួន ក្រុមការងារបានធ្វើទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំដើម្បីទទួលបានការចុះ ហត្ថលេខាលើលិខិតចំលងដែលផ្តល់មកពីក្រសួងមហាផ្ទៃ។ លិខិតដែលចេញពីរដ្ឋអំណាចខេត្ត បានផ្តល់លទ្ធភាពងាយ ស្រួលក្នុងទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ (នៅខេត្ត កណ្តាល និងស្វាយរៀង)។

- ដោយឃើញច្បាប់បោះឆ្នោតព្រឹទ្ធសភា ចុះថ្ងៃទី ២០ មិថុនា ២០០៥ មណ្ឌលបោះឆ្នោតទាំងអស់ត្រូវបានបែងចែក ជា ៨ ភូមិភាគ ក្នុង ២៤ ខេត្ត/ក្រុង។ ១៤ ខេត្ត/ក្រុង ត្រូវបានជ្រើសរើសសំរាប់ការអង្កេតតាមរយៈ “Cluster Sampling” ក្នុងនោះតំបន់ទី១ គឺភ្នំពេញ តំបន់ទី២ និងទី៣ គឺកំពង់ចាម តំបន់ទី៤ គឺបន្ទាយមានជ័យ និង បាត់ដំបងតំបន់ទី៥ គឺតាកែវ កំពត និងក្រុងព្រះសីហនុ តំបន់ទី៦ គឺព្រៃវែង តំបន់ទី៧ គឺកំពង់ឆ្នាំង កំពង់ស្ពឺ និង ពោធិសាត់ និងតំបន់ ទី៨ គឺ រតនៈគីរី ក្រចេះ និងកំពង់ធំ។ ជាដំបូង **ខុមហ្វ្រែល** បានធ្វើការអង្កេតនៅក្នុង ១៤

ខេត្ត/ក្រុង បន្ទាប់មក **ខុមហ្វ្រែល** បានធ្វើការអង្កេតខេត្ត/ក្រុង ដែលនៅសល់។ លទ្ធផលនៃការស្រាវជ្រាវ បានបង្ហាញអោយឃើញថា ចំលើយនៃការវាយតំលៃនៅក្នុង ១៤ ខេត្ត/ក្រុង ចេញពី (Cluster sampling នៃភូមិភាគ) មានលក្ខណៈប្រហាក់ប្រហែលគ្នា នឹងលទ្ធផលនៃ ការវាយតំលៃក្នុង ២៤ ខេត្ត/ក្រុងដែរ។

## ៥. សង្ខេបលទ្ធផលស្រាវជ្រាវ

**"អ្នកផ្តល់បទសម្ភាសន៍"** គឺសំដៅទៅលើអ្នកបោះឆ្នោតដែលត្រូវបានសម្ភាសន៍ និងកំណត់ដោយក្រុមការងារ (អ្នកមានសិទ្ធិបោះឆ្នោតរួមទាំងអ្នកបានចុះឈ្មោះបោះឆ្នោត)

**"ចម្លើយ"** សំដៅទៅលើចម្លើយរបស់អ្នកផ្តល់បទសម្ភាសន៍ (អ្នកសម្ភាសន៍ម្នាក់ៗ អាចមានចម្លើយលើសពី ១)

**"ភាពមិនត្រឹមត្រូវ"** គឺសំដៅទៅលើព័ត៌មានរបស់អ្នកបោះឆ្នោត (ឈ្មោះ ភេទ ឬឆ្នាំកំណើត) នៅក្នុងបញ្ជីបោះឆ្នោតខុសពីឯកសារអត្តសញ្ញាណ របស់អ្នកបោះឆ្នោត ហើយដែលអាចនាំឱ្យបាត់បង់សិទ្ធិបោះឆ្នោត។

- ការសិក្សាស្រាវជ្រាវបង្ហាញថាភាគរយនៃស្ត្រី និងបុរស ដែលបានបោះឆ្នោតមានប្រហាក់ប្រហែលគ្នា។ ចំនួននៃអ្នកបោះឆ្នោតជាយុវជន ដែលមានអាយុពី ១៨ - ៣០ឆ្នាំ ដែលបានចូលរួមក្នុងការបោះឆ្នោតមានកំរិតទាបជាងអ្នកបោះឆ្នោតដែលមានវ័យចំណាស់។ ភាគរយនៃអ្នកដែលបានចូលរួមបោះឆ្នោតឆ្នាំ ២០០៨ មានការកើនឡើងជាងឆ្នាំ ២០០៧ ក្នុងនោះ អ្នកបានបោះឆ្នោតស្ត្រីមានការកើនឡើង ៨,៤% និងបុរសមានការកើនឡើង ៥,៦៣%។ យ៉ាងណាមិញ ភាគរយនៃអ្នកបោះឆ្នោតជាយុវជនមានការថយចុះ ០,២៥%។

- ផ្អែកលើការស្រាវជ្រាវក្នុងចំណោមអ្នកបានផ្តល់បទសម្ភាសន៍ដែលមិនបានបោះឆ្នោត មាន ២១,៤%នៃអ្នកមានសិទ្ធិបោះឆ្នោតតែមិនបានបោះឆ្នោត បានទៅការិយាល័យបោះឆ្នោតដើម្បីបោះឆ្នោតឆ្នាំ ២០០៨ ក៏ប៉ុន្តែពួកគាត់ទាំងនោះពុំបានបោះឆ្នោតទេ (ភាគច្រើនធ្លាប់បានបោះឆ្នោតឆ្នាំ ២០០៣ ឬ/និង ២០០៧)។ ប្រសិនបើបញ្ជីបោះឆ្នោតឆ្នាំ ២០០៧ មានភាពត្រឹមត្រូវ ១០០% យើងអាចគណនាចេញជាតួលេខថា មានអ្នកបោះឆ្នោតប្រមាណ ៤៤០.០០០ នាក់ (ដែលភាគច្រើនបានបោះឆ្នោតឆ្នាំ២០០៣ និង/ឬ២០០៧) បានចេញទៅបោះឆ្នោត ប៉ុន្តែមិនអាចបោះឆ្នោតបានដោយសារតែឧបសគ្គមួយចំនួន ជាពិសេសគឺមិនអាចរកឈ្មោះ ឬការិយាល័យបោះឆ្នោតឃើញ។ ប៉ុន្តែប្រសិនបើបញ្ជីបោះឆ្នោតឆ្នាំ២០០៧ មិនមានភាពត្រឹមត្រូវ១០០%ទេ នោះចំនួននេះអាចតិចជាង ដោយសារតែបញ្ជីបោះឆ្នោតមានឈ្មោះ "អ្នកបោះឆ្នោតខ្មោច" ឬ/និង "ឈ្មោះស្ទួន"។ បញ្ហាដែលបង្កអោយមានការរាំងស្ទះក្នុងការបោះឆ្នោតរបស់ពួកគាត់មានដូចជាៈ ៣៦,១% នៃចំលើយរបស់អ្នកត្រូវសម្ភាសន៍ ទៅដល់ការិយាល័យតែមិនបានបោះឆ្នោតគឺពួកគេរកឈ្មោះមិនឃើញនៅ ក្នុងបញ្ជីឈ្មោះបោះឆ្នោត បើទោះជាអ្នកទាំងនោះធ្លាប់បានចូលរួមបោះឆ្នោតមុនៗក៏ដោយ។ ២០.១% រកឈ្មោះ ឬ ការិយាល័យបោះឆ្នោតពុំឃើញដោយសារពួកគាត់គ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត។ ៧,៦% មិនបានយកប័ណ្ណព័ត៌មាន អ្នកបោះឆ្នោតទៅជាមួយ ហើយត្រូវបានគេប្រាប់ថាមិនអាច បោះឆ្នោតបានទេ។ ២,៨% ត្រូវបានហាមឃាត់មិនអោយ ចូលទៅក្នុងការិយាល័យបោះឆ្នោតដោយអាជ្ញាធរ ឬភ្នាក់ងាររបស់គណបក្សនយោបាយ។ ២,៨% មិនចង់ឈរ តំរង់ជួរចាំ។ ៨,៣% មិនអាចបោះឆ្នោតបានដោយសារខុសព័ត៌មានក្នុងបញ្ជីបោះឆ្នោតផ្លូវការ។ ៨,៣% បានបាត់ ឬក៏ គ្មានឯកសារអត្តសញ្ញាណ ឬប័ណ្ណស្នាក់នៅ និង០,៧% បានទៅការិយាល័យបោះឆ្នោត ក៏ប៉ុន្តែឈ្មោះរបស់គាត់ត្រូវបាន បោះឆ្នោតជំនួសដោយអ្នកផ្សេង។

- ក្នុងចំណោមអ្នកបានផ្តល់បទសម្ភាសន៍ដែលបានបោះឆ្នោតក្នុងឆ្នាំ២០០៨ បានបង្ហាញថា អ្នកត្រូវការប្រើប្រាស់ទំរង់ ១០១៨ មានចំនួន៧,២% និង៩២,៨% បានប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងៗ។ ប្រសិនបើយើង គណនាចេញពីអ្នកដែលបានបោះឆ្នោតឆ្នាំ ២០០៨ ប្រមាណជាង ៦ លាននាក់ នោះអ្នកបានចុះឈ្មោះបោះឆ្នោត ប្រមាណ ៤៤០.០០០នាក់បានប្រើទម្រង់ ១០១៨ ដើម្បីបោះឆ្នោតនៅឆ្នាំ២០០៨។ នៅក្នុងចំណោមអ្នកដែលបាន ប្រើប្រាស់ទំរង់ ១០១៨នេះ មាន ៧៤,១% ដោយសារតែគាត់គ្មានឯកសារបញ្ជាក់អត្តសញ្ញាណសំរាប់ការបោះឆ្នោត។ ១១,៣% ប្រើប្រាស់ទំរង់១០១៨ ដោយសារត្រូវការកែតំរូវព័ត៌មានឱ្យដូចក្នុងបញ្ជីបោះឆ្នោត និង១៤,៦% មានបញ្ហា ផ្សេងៗ ក្នុងនោះរាប់បញ្ចូលអ្នកដែលបានបាត់ឯកសារបញ្ជាក់អត្តសញ្ញាណសំរាប់ការបោះឆ្នោត ។ល។ ក្នុងចំណោមអ្នក មានសិទ្ធិបោះឆ្នោតដែលបានសម្ភាសន៍ មាន ៧៣% បានឆ្លើយថា ពេញចិត្តនឹងការប្រើប្រាស់ឯកសារបញ្ជាក់អត្ត សញ្ញាណដូចសព្វថ្ងៃសំរាប់ការបោះឆ្នោតនាពេលខាងមុខ ហើយមាន១៣,៣%ស្នើរអោយធ្វើប័ណ្ណបោះឆ្នោតដូចជាប័ណ្ណ ដែលបានប្រើប្រាស់នៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៨។

- ៩០,៧% នៃអ្នកមានសិទ្ធិបោះឆ្នោតបានទទួលបាននូវប័ណ្ណព័ត៌មានអ្នកបោះឆ្នោត។ រីឯក្នុងចំណោមអ្នកដែលមិនបាន ទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោតវិញ គឺមាន ៤,៩% ពុំបានចូលរួមក្នុងការបោះឆ្នោតឆ្នាំ ២០០៨ ក្នុងនោះមាន ៤០,៤% ជាស្ត្រី និង ៥៩,៦% ជាបុរស ហើយ ៥៦,៧% នៃអ្នកមិនបានទទួលប័ណ្ណព័ត៌មាន គឺជាយុវជនដែលមាន អាយុពី ១៨-៣០ ឆ្នាំ ។

- ៩២,៦% នៃអ្នកមានសិទ្ធិបោះឆ្នោតដែលដឹងពីការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅក្នុងភូមិរបស់គាត់ មានការ ពេញចិត្ត និងគាំទ្រទៅលើដំណើរការនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត។ រីឯក្នុងចំណោមអ្នកមិនពេញចិត្តទៅនឹង វិធីសាស្ត្រក្នុងការចែកចាយប័ណ្ណព័ត៌មានវិញមាន៥៣,៩% បានសំណូមពរអោយ គ.ជ.ប តែមួយគត់ត្រូវទទួលខុសត្រូវ ដោយអោយមនុស្សឯករាជ្យរបស់ខ្លួនជាអ្នកចែកដល់អ្នកបោះឆ្នោត។

- ក្នុងការធ្វើបទសម្ភាសន៍អ្នកមានសិទ្ធិបោះឆ្នោតបានបង្ហាញថា ពួកគាត់មានការព្រួយបារម្ភក្នុងករណីដែលលទ្ធផល នៃការបោះឆ្នោតបានបង្ហាញអោយដឹងថា អ្នករស់នៅក្នុងភូមិ ឬឃុំនេះបានគាំទ្រឱ្យគណបក្សនយោបាយណាមួយ ក្រោយពេលការបោះឆ្នោតហើយ។ **២៣,៩%** មានការព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេគឺ **២,៨%** មានការព្រួយបារម្ភខ្លាំង និង **២១,១%** មានការព្រួយបារម្ភខ្លះៗ។

- **៨៤,២%** នៃអ្នកមានសិទ្ធិបោះឆ្នោត មិនថាប្រុស ឬស្រី ពុំមានអារម្មណ៍ធុញទ្រាន់នឹងការចុះឈ្មោះ ឬពិនិត្យបញ្ជី ឈ្មោះទេ។

- ចំលើយនៃអ្នកត្រូវសម្ភាសន៍ បានឱ្យដឹងថា ពីមិត្តភ័ក្រ្ត គ្រួសារ ឬអ្នកជិតខាងរបស់អ្នកបោះឆ្នោត ឬក៏អ្នកបោះឆ្នោត ខ្លួនឯងបានអោយ ដឹងថា ពួកគេបានជួបប្រទះនូវភាពមិនប្រក្រតីមួយចំនួននៅក្នុងការបោះឆ្នោតឆ្នាំ២០០៨។ ក្នុងនោះ

មានចំលើយ ដូចជា ការផ្តល់ អំណោយ ឬថវិកាដោយបញ្ជាក់អោយបោះឆ្នោតទៅគណបក្សនយោបាយណាមួយមានចំនួន**៦១,៥%** អំពើហឹង្សា ប្រឆាំងអ្នកគាំទ្រ ឬសកម្មជនគណបក្សនយោបាយមានចំនួន**៥,៣%** ការគំរាមគំហែងមានចំនួន **១២,៦%** ការលប់ ឈ្មោះអ្នកបោះឆ្នោតមានចំនួន**២៩,២%** ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយលំអៀង មាន **១៤,៣%** គ្មានការសម្ងាត់មាន **៣,៦%** មានការបង្ខំអោយអ្នកបោះឆ្នោតស្បថបោះឆ្នោតអោយគណបក្សរបស់ខ្លួនមាន**៧,៩%** និងករណីមួយចំនួន ផ្សេងទៀត។

- នៅក្នុងការធ្វើសវនកម្មបញ្ជីបោះឆ្នោតឆ្នាំ២០០៨ ភាពមិនត្រឹមត្រូវនៃបញ្ជីបោះឆ្នោតឆ្នាំ២០០៨ ភាគច្រើនទាក់ទងនឹងថ្ងៃខែឆ្នាំកំណើត(១៣,៨%) ឈ្មោះមានចំនួន ៧,២០%។ ហើយអ្នកបោះឆ្នោត ១៨.១០% មានការខុសព័ត៌មាន (ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ឬភេទ) ទៅលើចំនុចណាមួយយ៉ាងតិចនៅក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០០៨។ រីឯអ្នកបោះឆ្នោតចំនួន១៨,៥% (១៦,៣% បានបោះឆ្នោតនៅក្នុងឆ្នាំ២០០៧ និង/ឬ២០០៨ ហើយ ២,២%ទៀត ជាអ្នកបោះឆ្នោតទើបនឹងចុះឈ្មោះថ្មី) មិនមានទិន្នន័យណាមួយ រាប់បញ្ចូលទាំងឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០០៨ទេ។ ករណីនេះកើតឡើងដោយសារៈ

  - អ្នកបោះឆ្នោតបានផ្លាស់ប្តូរលំនៅដ្ឋាន នាំឱ្យមានភាពមិនត្រឹមត្រូវនៅលើអាសយដ្ឋាន ឬគ្មានទិន្នន័យក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ ២០០៨។
  - អ្នកបោះឆ្នោតមិនបានទៅផ្ទៀងផ្ទាត់ព័ត៌មានរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ។
  - ប្រតិបត្តិការរបស់ គ.ជ.ប និងការគ្រប់គ្រងទិន្នន័យក្នុងកុំព្យូទ័រមានបញ្ហាទាក់ទងនិងការគ្រប់គ្រង គុណភាព។
  - ស្មៀនឃុំបំពេញព័ត៌មានខុស ហើយបញ្ជូនព័ត៌មានខុសនេះទៅអោយ គ.ជ.ប។
  - ការភាន់ច្រឡំរវាង ក្រុមប្រឹក្សាឃុំ សង្កាត់ (ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ) និង គ.ជ.ប ចំពោះការគ្រប់គ្រងលើក្រុមប្រឹក្សាឃុំ/សង្កាត់ ទាក់ទងការងារបោះឆ្នោត។

## ៦. អនុសាសន៍

### ក. ការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត

ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតប្រចាំឆ្នាំដោយក្រុមប្រឹក្សាឃុំ សង្កាត់គួររក្សាទុកដដែល។ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានឯកសារបញ្ជាក់គ្រប់គ្រាន់មុននឹងធ្វើបច្ចុប្បន្នភាព ឬលុបឈ្មោះអ្នកបោះឆ្នោតដែលផ្លាស់ប្តូរទីលំនៅទៅឃុំផ្សេង ឬស្លាប់។ ដោយសារតែការបោះឆ្នោត ត្រូវ បានធ្វើឡើងជារៀងរាល់ ៥ឆ្នាំ ដូចនេះនៅក្នុងអំឡុងឆ្នាំបោះឆ្នោត គ.ជ.ប ត្រូវសហការជាមួយប្រធានក្រុម ប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានសមាសភាពចំនួនពីររូប (មកពីគណបក្សនយោបាយផ្សេងគ្នា) ស្មៀនឃុំ សង្កាត់ និងអាជ្ញាធរមូលដ្ឋានផ្សេងៗទៀតត្រូវទទួលខុសត្រូវរៀបចំការចុះឈ្មោះអ្នកបោះឆ្នោត

និងធ្វើបច្ចុប្បន្នភាព បញ្ជីបោះឆ្នោតពិសេសមួយសម្រាប់ការបោះឆ្នោត។ រយៈពេលការចុះឈ្មោះអ្នកបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ពិសេសនេះគួរត្រូវបន្ថែមដល់១២០ថ្ងៃ ដើម្បីឱ្យប្រជាពលរដ្ឋមានពេលវេលាច្រើនចុះឈ្មោះបោះឆ្នោត និងពិនិត្យកែតម្រូវទិន្នន័យក្នុងបញ្ជីបោះឆ្នោត។ គ.ជ.ប គួរតែងតាំងបុគ្គលិករបស់ខ្លួនជាប្រធាន/អ្នកគ្រប់គ្រងក្នុងការចុះឈ្មោះអ្នកបោះឆ្នោតថ្នាក់ឃុំ សង្កាត់។ យុទ្ធនាការថ្នាក់ជាតិត្រូវតែធ្វើឡើងដើម្បីផ្សព្វផ្សាយ និងជម្រុញអ្នកបោះឆ្នោតឱ្យទៅចុះឈ្មោះបោះឆ្នោត ពិនិត្យឈ្មោះ និងកែតម្រូវព័ត៌មានក្នុងបញ្ជីបោះឆ្នោតក្នុងករណីខុសពីឯកសារ អត្តសញ្ញាណពិតប្រាកដរបស់ខ្លួន។ យុទ្ធនាការនេះ អាចធ្វើឡើងដោយ គ.ជ.ប គណបក្សនយោបាយ រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ឬ/និងភាគីពាក់ព័ន្ធការបោះឆ្នោតនានា។ លើសពីនេះទៅទៀត អង្គការសង្កេតការណ៍បោះឆ្នោត និងគណបក្សនយោបាយអាចធ្វើការអង្កេតទៅលើដំណើរការចុះឈ្មោះអ្នកបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតពិសេសនេះ។

ការប្រគល់ការទទួលខុសត្រូវការចុះឈ្មោះបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតនេះទៅឱ្យ គ.ជ.ប ក៏ដោយសារតែតាមលទ្ធផលអង្កេតបង្ហាញថា អ្នកមានសិទ្ធិបោះឆ្នោតជាង ៥០% (ក្នុងចំណោមអ្នកជួបបញ្ហា) មានការជឿជាក់ទៅលើការងាររបស់ គ.ជ.ប តែមួយគត់។ ហើយក្នុងការអង្កេតនៅក្នុងការបោះឆ្នោតឆ្នាំ ១៩៩៨ និង២០០២ បង្ហាញថា ការចុះឈ្មោះបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតដែលធ្វើឡើងដោយ គ.ជ.ប គឺមានភាពត្រឹមត្រូវច្រើនជាងប្រព័ន្ធបច្ចុប្បន្ន។

អង្គការមិនមែនរដ្ឋាភិបាលដែលជាស្ថាប័នឯករាជ្យគួរធ្វើសវនកម្មបញ្ជីបោះឆ្នោត ដើម្បីផ្តល់ព័ត៌មានពីភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត មុននឹងមានការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតពិសេសនេះ។ ព័ត៌មាននៅក្នុងបញ្ជីបោះឆ្នោត (ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ) គួរតែត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងអត្តសញ្ញាណប័ណ្ណដែលចេញដោយក្រសួងមហាផ្ទៃ។ គ.ជ.ប ត្រូវប្រើព័ត៌មាននេះដើម្បីផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត។ ទោះបីយ៉ាងណា គ.ជ.ប ត្រូវធ្វើទំនាក់ទំនងជាមួយអ្នកចុះឈ្មោះបោះឆ្នោតដែលព័ត៌មានរបស់គាត់ត្រូវការធ្វើការកែតម្រូវ ឬបច្ចុប្បន្នភាព។ ជាមួយគ្នានេះ ក្រសួងមហាផ្ទៃ គួរតែសម្អាតទិន្នន័យរបស់ខ្លួនជាមុនសិន ដោយមានម្ចាស់ជំនួយមួយចំនួនដូចជា កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) កំពុងតែព្យាយាមគាំទ្រគម្រោងមួយដែលធ្វើទិន្នន័យអត្តសញ្ញាណតាមជីវសាស្ត្រ។

ប្រសិនបើការធ្វើសវនកម្មបញ្ជីបោះឆ្នោតរកឃើញថា ភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោតនៅក្រោម ៩០% (ទិន្នន័យមិនត្រឹមដូចជាឈ្មោះស្ទួន និងឈ្មោះខ្មោច) គ.ជ.ប ដោយសហការជាមួយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានចំនួនពីររូប (មកពីគណបក្សនយោបាយផ្សេងគ្នា) ស្មៀនឃុំ សង្កាត់ និងអាជ្ញាធរមូលដ្ឋានផ្សេងៗទៀត ត្រូវទទួលខុសត្រូវសម្អាតបញ្ជីបោះឆ្នោត។ នីតិវិធីនៃការសម្អាតបញ្ជីឆ្នោតត្រូវតែធ្វើការកែប្រែ។ គ.ជ.ប គួរប្រើប្រាស់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោតចុងក្រោយ ហើយរកឈ្មោះអ្នកដែលមិនបានបោះឆ្នោត។ ដូចនេះ គ.ជ.ប ត្រូវផ្តោតការយកចិត្តទុកដាក់តែជនដែលមិនបានបោះឆ្នោតដែលធ្វើឡើងក្រោយគេបានហើយ ដោយមិនចាំបាច់គិតពីអ្នកដែលបានបោះឆ្នោតនោះទេ។

## ខ. ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

អ្នកបោះឆ្នោតម្នាក់ៗត្រូវតែមានប័ណ្ណព័ត៌មានបោះឆ្នោត ដើម្បីដោះស្រាយឧបសគ្គធំៗនានានៅការិយាល័យបោះឆ្នោត ដែលជួបបញ្ហារកឈ្មោះ ឬការិយាល័យបោះឆ្នោតរបស់ខ្លួនមិនឃើញ។ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតត្រូវបានផលិតដោយមានអ៊ុតប្លាស្ទិក ហើយត្រូវមានព័ត៌មានអ្នកបោះឆ្នោត ជាពិសេសការិយាល័យ និងមណ្ឌលបោះឆ្នោត "ជាអចិន្ត្រៃយ៍"។ អ្នកបោះឆ្នោតត្រូវរក្សាប័ណ្ណព័ត៌មានទុកដូចជាប័ណ្ណដទៃទៀតដែរ។ ព័ត៌មានអ្នកបោះឆ្នោតអាចដូរបាន ក្នុងករណីដែលអ្នកបោះឆ្នោត ផ្លាស់ប្តូរលំនៅដ្ឋានទៅឃុំផ្សេងទៀត។ គ.ជ.ប ត្រូវរៀបចំបញ្ជីបោះឆ្នោតនៅការិយាល័យ បោះឆ្នោតណាដែលមានបញ្ហា (ឧទាហរណ៍ រៀបតាមអក្ខរក្រម ឬលេខកូដអ្នកបោះឆ្នោត លេខកូដការិយាល័យ) ហើយការផ្លាស់ប្តូរទាំងនេះត្រូវតែជូនដំណឹងដល់អ្នកបោះឆ្នោត។ ជាងនេះទៅទៀត ដោយឧបសគ្គចម្បងនានាដែលនាំឱ្យបោះឆ្នោតមិនបាន គឺ ទាក់ទងទៅនឹងការរកឈ្មោះ ឬ ការិយាល័យមិនឃើញ (៥៦% នៃចម្លើយ) ហើយដោយគិតទៅលើអ្នកបោះឆ្នោតប្រមាណ ៩% ដែលមិនបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត នោះការចែកប័ណ្ណព័ត៌មានគួរតែត្រូវធ្វើឡើងដោយ គ.ជ.ប ដោយសហការ ជាមួយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុម ប្រឹក្សាឃុំ សង្កាត់ ដោយមានចំនួនពីររូប (មកពីគណបក្សនយោបាយ ផ្សេងគ្នា) ស្មៀនឃុំ សង្កាត់ និងអាជ្ញាធរមូលដ្ឋានផ្សេងៗទៀត ដែលអ្នកបោះឆ្នោតចង់ឱ្យធ្វើកិច្ចការនេះ។ ហើយត្រូវធានាថា អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់ត្រូវទទួលបានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត។

## គ. ការចេញទម្រង់ ១០១៨

ក្រសួងមហាផ្ទៃ ដែលមានការគាំទ្រពីម្ចាស់ជំនួយ គួរព្យាយាមឱ្យអស់លទ្ធភាពដើម្បីចេញ និងចែកអត្តសញ្ញាណប័ណ្ណខ្មែរដល់គ្រប់ពលរដ្ឋកម្ពុជាឱ្យបានយ៉ាងយូរត្រឹមឆ្នាំ២០១១។ ប្រសិនបើអាចធ្វើបាន (ដោយអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចេញឱ្យពលរដ្ឋកម្ពុជាដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ) នោះអ្នកបោះឆ្នោតថ្មីទាំងអស់នឹងមានឯកសារ បញ្ជាក់អត្តសញ្ញាណដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោត។

ជាមួយគ្នានេះ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរភាគច្រើននឹងផុតកំណត់នៅក្នុងឆ្នាំ២០១២ ហើយប្រសិនបើក្រសួងមហាផ្ទៃមិនអាចចេញ និងចែកអត្តសញ្ញាណប័ណ្ណឱ្យពលរដ្ឋខ្មែរបាន១០០%ទេ នោះត្រូវមានវិធានការ២យ៉ាង: ១)ក្រសួងមហាផ្ទៃ និងគ.ជ.ប គួរធ្វើសេចក្តីណែនាំ និងផ្សព្វផ្សាយជាសាធារណៈថា អត្តសញ្ញាណប័ណ្ណដែលផុតកាលកំណត់អាចប្រើប្រាស់ជាឯកសារអត្តសញ្ញាណដើម្បីបោះឆ្នោតបាន។ ២)ទម្រង់ ១០១៨ ឬឯកសារអត្តសញ្ញាណបណ្តោះអាសន្នផ្សេងទៀតនៅតែចាំបាច់សម្រាប់អ្នកបោះឆ្នោត។ ទោះបីយ៉ាងណា ទម្រង់១០១៨ គួរតែត្រូវប្តូរទៅជាប័ណ្ណបោះឆ្នោតបណ្តោះអាសន្នវិញ។ ហើយការចេញប័ណ្ណនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ។ ប័ណ្ណនេះអាចប្រើប្រាស់សម្រាប់ការបោះឆ្នោត ២ដង គឺការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

ចំនួនអ្នកបោះឆ្នោតដែលគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអាចដឹងតាមរយៈការផ្ទៀងផ្ទាត់ទៅលើទិន្នន័យអ្នកបោះឆ្នោត (មាននៅក្នុងអនុសាសន៍ចំនុច **ក**)។

## ឃ. ការកាត់បន្ថយការភ័យខ្លាច

ដើម្បីឆ្លើយតបទៅនឹងការភ័យខ្លាចរបស់អ្នកបោះឆ្នោត វាចាំបាច់ត្រូវមានការកាត់បន្ថយនូវឥទ្ធិពលរបស់អាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធ។ ក្នុងករណីនេះចាំបាច់ត្រូវ ១) ធ្វើវិសោធនកម្មនីតិវិធីជ្រើសរើសមេភូមិឱ្យទៅជាការបោះឆ្នោតដោយផ្ទាល់ និងសាមញ្ញដោយអ្នកភូមិដើម្បីកាត់បន្ថយភាពមិនលំអៀងរបស់មេភូមិ។ ២) ពង្រឹងការអនុវត្ត និងបង្កើនការយល់ដឹងរបស់មេភូមិ និងអាជ្ញាធរភូមិទៅលើគោលការណ៍ណែនាំរបស់ គ.ជ.ប និងក្រសួងមហាផ្ទៃដើម្បីធានាពីអព្យាក្រឹតភាពរបស់មេភូមិ និងការបំពេញតួនាទីដ៏មានប្រសិទ្ធិភាពក្នុងអំឡុងពេលបោះឆ្នោត។ ៣) ពង្រឹងការអនុវត្តច្បាប់ស្តីពីមន្ត្រីយោធា នគរបាល និងបញ្ជាក់ពីបទបញ្ញត្តិបោះឆ្នោតរបស់ គ.ជ.ប ដើម្បីធានាពីអព្យាក្រឹតភាពរបស់អាជ្ញាធរ និងមន្ត្រីប្រដាប់អាវុធនានា រួមទាំងនគរបាលដើម្បីមិនឱ្យចូលរួមនៅក្នុងសកម្មភាពគណបក្សនយោបាយណាមួយ និងយុទ្ធនាការឃោសនាបោះឆ្នោតទាំងពេលក្នុង និងក្រៅម៉ោងការងារ។

## ង. ការកាត់បន្ថយភាពមិនប្រក្រតីទាក់ទងនឹងការទិញសន្លឹកឆ្នោត

ចម្លើយរបស់អ្នកបោះឆ្នោតបានឱ្យដឹងថា ៦១% មានបទពិសោធន៍ទាក់ទងនឹងការទិញសន្លឹកឆ្នោត។ ដើម្បីកាត់បន្ថយភាពមិនប្រក្រតីទាក់ទងនឹងការទិញសន្លឹកឆ្នោត បទបញ្ញត្តិ និងច្បាប់បោះឆ្នោតត្រូវតែធ្វើវិសោធនកម្មដោយបន្ថែមការបញ្ជាក់ឱ្យច្បាស់ និងការពិន័យទាក់ទងនឹងការទិញសន្លឹកឆ្នោត និងការសន្យាឱ្យថវិកា និងបញ្ជាក់បន្ថែមឱ្យច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ គ.ជ.ប នៅក្នុងច្បាប់បោះឆ្នោតទាក់ទងនឹងការត្រួតពិនិត្យ និងការផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ហិរញ្ញវត្ថុរបស់គណបក្សនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត។ គ.ជ.ប គួរមាននីតិវិធីព្រមានច្បាស់លាស់ទាក់ទងនឹងការប៉ុនប៉ង និងសកម្មភាពជាក់ស្តែងក្នុងការទិញសន្លឹកឆ្នោត ដូចជាការចេញកាតលឿង ឬក្រហមសម្រាប់បេក្ខជន ឬគណបក្សនយោបាយណាដែលរកឃើញ ថាមានកំហុសទិញសន្លឹកឆ្នោត (កាតលឿង គឺជាការព្រមាន ហើយកាតក្រហមគឺមានន័យថាបេក្ខជន ឬគណបក្សនយោបាយ មិនអាចឈរឈ្មោះបោះឆ្នោតបានទេ)។

## ច. កាត់បន្ថយភាពលំអៀងនៃប្រព័ន្ធផ្សព្វផ្សាយ

១៤% នៃចំលើយអ្នកត្រូវសំភាសន៍និយាយថា ប្រព័ន្ធផ្សព្វផ្សាយមានភាពលំអៀង។ ដើម្បីកាត់បន្ថយភាពលំអៀងរបស់ប្រព័ន្ធ ផ្សព្វផ្សាយចំពោះគណបក្សណាមួយ ក្របខណ្ឌគោលនយោបាយ ឬច្បាប់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយគួរត្រូវបានបង្កើតឡើង និងពង្រឹងតាម "គោលការណ៍សមធម៌" និងព័ត៌មានដែលមានតុល្យភាពសម្រាប់គណបក្សសំខាន់ៗក្នុងអំឡុងពេលបោះឆ្នោត (ឬកំឡុងពេលប្រតិទិនបោះឆ្នោតរបស់ គ.ជ.ប)។ **ខុមហ្វ្រែល** គាំទ្រអនុសាសន៍របស់សហគមន៍អឺរ៉ុបដែលថែង

ថា "រាជរដ្ឋាភិបាលត្រូវតែ បង្ហាញការប្ដេជ្ញាចិត្តរបស់ខ្លួនដើម្បីធានានូវបរិយាកាសប្រព័ន្ធផ្សព្វផ្សាយសេរីតាមរយៈ ការបង្កើតនូវអាជ្ញាធរត្រួតពិនិត្យការ ផ្សាយឯករាជ្យមួយសម្រាប់ការផ្ដល់អាជ្ញាប័ណ្ណ និងរលកអាកាសដល់ប្រព័ន្ធផ្សព្វផ្សាយតាម វិទ្យុ និងទូរទស្សន៍ ដោយឈរលើ មូលដ្ឋានបើកចំហ និងមានតម្លាភាព។"

## ៧. វិភាគទិន្នន័យ

### ៧.១ ការចូលរួមបោះឆ្នោតតាម ភេទ និងអាយុ

**តារាងទី ២: ការចូលរួមបោះឆ្នោតតាម ភេទ និងអាយុ**

| ល.រ | បរិយាយ | បោះឆ្នោតជ្រើសរើសសមាជិក ឃុំ សង្កាត់ ២០០៧ | បោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រ ២០០៨ |
|---|---|---|---|
| ១ | ស្ត្រី | ៨៣,០៣% | ៩១,៧% |
| ២ | ប្រុស | ៨៦,៣៧% | ៩២% |
| ៣ | យុវជនអាយុ (១៨-៣០ ឆ្នាំ) | ៨៧,៤៥% | ៨៧,២% |

តារាងទី ២ បានបង្ហាញអោយឃើញថា អ្នកបោះឆ្នោតទាំងពីរភេទ (ស្រី និងប្រុស) មានភាគរយប្រហាក់ប្រហែលគ្នាដែលបានចូលរួមការក្នុងការបោះឆ្នោត។ តាមទិន្នន័យរបស់ គ.ជ.ប បានអោយដឹងថា អ្នកចុះឈ្មោះបោះឆ្នោតភេទស្រីមានប្រមាណ ៤,៣០ លាននាក់ (៥៣%) និងអ្នកចុះឈ្មោះបោះឆ្នោតភេទប្រុសមានប្រមាណ ៣,៨២ លាននាក់ (៤៧%)។ ដូចនេះ ចំនួនអ្នកបានបោះឆ្នោតជាស្ត្រីគឺមានច្រើនជាងបុរស។

តារាងទី ២ ក៏បង្ហាញអោយឃើញដែរថា ចំនួនអ្នកបោះឆ្នោតវ័យក្មេងដែលមានអាយុចាប់ពី ១៨-៣០ ឆ្នាំ បានចូលរួមការបោះឆ្នោតមានចំនួនទាបជាងអ្នកបោះឆ្នោតដែលមានវ័យចំណាស់ជាង។

បើយើងធ្វើការប្រៀបធៀបភាគរយនៃអ្នកដែលបានចូលរួមក្នុងការបោះឆ្នោតឆ្នាំ ២០០៧ និង ២០០៨ ធៀបទៅនឹងភេទអ្នកបោះឆ្នោត យើងសង្កេតឃើញថា នៅក្នុងការបោះឆ្នោតជាតិឆ្នាំ ២០០៨ អ្នកបោះឆ្នោតភេទស្រីមានការកើន ឡើង ៨,៤% និងអ្នកបោះឆ្នោតភេទប្រុសមានការកើនឡើង ៥,៦៣% ខណៈដែលអ្នកបោះឆ្នោតយុវជនមានការធ្លាក់ចុះ ០,២៥%។

### ៧.២ មូលហេតុដែលបណ្ដាលអោយអ្នកបោះឆ្នោតមិនបានបោះឆ្នោត

**រូបភាពទី ១: អ្នកបោះឆ្នោតដែលមិនបានបោះឆ្នោតនៅថ្ងៃបោះឆ្នោត (សំណួរទី១)**




នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ មានប្រជាពលរដ្ឋចំនួនប្រមាណ **២.១លាននាក់** ក្នុងចំណោមអ្នកបានចុះឈ្មោះបោះឆ្នោត **៨.១២ លាននាក់** មិនបានបោះឆ្នោត។ នេះបើគណនាចេញពីចំនួនអ្នកចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០០៧ និងចំនួនអ្នកបានបោះឆ្នោតឆ្នាំ ២០០៨។ រូបភាពទី ១ បង្ហាញថា ក្នុងចំណោមអ្នកដែលមិនបានបោះឆ្នោត ឆ្នាំ ២០០៨ មាន ២១.៤% ឬប្រមាណ ៤៤០.០០០ នាក់ (យើងអាចគណនាចេញជាចំនួន ៤៤០.០០០ នាក់ នៅទូទាំងប្រទេសក្នុងករណីដែលបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ ២០០៧ មានភាពត្រឹមត្រូវ ១០០% គឺគ្មានឈ្មោះខ្មោច ឬ/និងឈ្មោះស្ទួន។ ទោះបីយ៉ាងណា ចំនួននេះអាចទាបជាងនេះ ប្រសិនបើបញ្ជីបោះឆ្នោតឆ្នាំ២០០៧ មានឈ្មោះខ្មោច ឬ/និងឈ្មោះស្ទួន) បានទៅការិយាល័យបោះឆ្នោតដើម្បីបោះឆ្នោត ប៉ុន្តែពួកគេមិនអាចបោះឆ្នោតបាន។ ចំណែក **៧៨.៦%** ទៀតមិនបានទៅការិយាល័យបោះឆ្នោតទេ។

## ៧.៣ ករណីដែលមិនបានទៅការិយាល័យបោះឆ្នោត

**តារាងទី ៣** បានបង្ហាញអោយឃើញថា ក្នុងចំណោមចំលើយនៃ**អ្នកមិនបានទៅការិយាល័យបោះឆ្នោត** ក៏ដូចជា**អ្នកមិនបានចូល រួមក្នុងការបោះឆ្នោត** គឺបណ្តាលមកពីករណីជាច្រើន ដូចជា:

- **២១.៣%** បង្ហាញថា គាត់មានទីលំនៅឆ្ងាយពីការិយាល័យបោះឆ្នោត
- **១៩.៥%** មិនអាចដើរទៅបោះឆ្នោតបានព្រោះគាត់ ជាជនពិការ ចាស់ជរា ឬមានអ្នកមានជំងឺ
- **១៥%** គាត់គិតថា ពុំមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត
- **៩.៤%** ពុំបានទទួលព័ត៌មានអំពីការបោះឆ្នោត
- **៩.៦%** ពុំបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ហើយអ្នកទាំងនោះគិតថាពុំមានសិទ្ធិបោះឆ្នោត

- **២,៥%** គឺម្ចាស់ក្រុមហ៊ុន ឬរោងចក្រ ឬថៅកែមិនអនុញ្ញាតអោយទៅបោះឆ្នោត
- **៤,៣%** គឺអ្នកបោះឆ្នោតខ្លួនឯងពុំមានចំណាប់អារម្មណ៍ក្នុងការចូលរួមបោះឆ្នោត
- **១,១%** ពុំបានបោះឆ្នោតដោយពុំចង់ចំណាយទៅលើតំលៃរថយន្ត ឈ្នួលថ្លៃពេក និង
- **៥២,១%** ដោយសារករណីផ្សេងៗ ដូចជាផ្លាស់ប្តូរទីលំនៅ បាត់ឯកសារអត្តសញ្ញាណ ធ្វើការនៅឆ្ងាយ ។ល ។

**តារាងទី ៣: ចំលើយអ្នកបោះឆ្នោតដែលមិនបានទៅការិយាល័យបោះឆ្នោត (សំណួរទី២)**

| ល.រ | បញ្ហាផ្សេងៗ | សរុប | |
|---|---|---|---|
| | | ចំនួន | % |
| ១ | អត់ដឹង ឬគ្មានព័ត៌មានអំពីការបោះឆ្នោត | ៥២ | ៩,៣៩% |
| ២ | ខ្ញុំនៅឆ្ងាយពីការិយាល័យបោះឆ្នោត | ១១៨ | ២១,៣% |
| ៣ | មិនបានទទួលប័ណ្ណព័ត៌មានបោះឆ្នោត (គេប្រាប់ថាគ្មានសិទ្ធិបើមិនមានប័ណ្ណ) | ៥៣ | ៩,៦% |
| ៤ | កន្លែងធ្វើការមិនអនុញ្ញាតអោយទៅបោះឆ្នោត | ១៤ | ២,៥% |
| ៥ | ខ្ញុំអស់ទឹកចិត្ត មិនចង់ទៅបោះឆ្នោត | ២៤ | ៤,៣% |
| ៦ | មិនអាចដើរទៅបោះឆ្នោតបាន ( ឈឺ ចាស់ពេក ឬពិការ) | ១០៨ | ១៩,៥% |
| ៧ | ខ្ញុំគិតថាគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ព្រោះខ្ញុំមិនបានទៅពិនិត្យ | ៨៣ | ១៥% |
| ៨ | រថយន្តឈ្នួលមានតំលៃថ្លៃពេក | ៦ | ១,១% |
| ៩ | ផ្សេងៗ | ២៨៨ | ៥២,១% |

នៅក្នុង**តារាងទី ៤** បានបង្ហាញអោយឃើញថា ក្នុងចំណោមចំលើយរបស់ស្ត្រីដែលមិនបានចេញទៅបោះឆ្នោត មាន **១៩,១**% ដោយសារតែផ្ទះរបស់គាត់ស្ថិតនៅឆ្ងាយពីការិយាល័យបោះឆ្នោត ហើយនិង **២១,៧**%មិនអាចទៅបោះឆ្នោតបាន ដោយសារគាត់ជាមនុស្សចាស់ជរា ជនពិការ ឬក៏ជាអ្នកមានជំងឺ ។

**តារាង ៤** ក៏បានបង្ហាញអោយឃើញថា ចម្លើយ **២៥,២**% នៃបុរសដែលមិនបានចេញទៅបោះឆ្នោត និង**២២,៣%** នៃយុវជនដែលមិនបានចេញទៅបោះឆ្នោត ក៏ដោយសារតែទីលំនៅរបស់គាត់នៅឆ្ងាយពីការិយាល័យបោះឆ្នោតដែរ ។ ក្នុងតារាងនេះផងដែរ បានបង្ហាញអោយឃើញថា **១៣,៤%**នៃអ្នកមានសិទ្ធិបោះឆ្នោតជាបុរសដែលមិនបានចេញទៅបោះឆ្នោត គឺពុំទទួលបានព័ត៌មានស្តីពីការបោះឆ្នោត ។ រីឯ **១៤,៨**% នៃអ្នកមានសិទ្ធិបោះឆ្នោតជាស្ត្រីដែលមិនបានចេញទៅបោះឆ្នោត និង **១៩,៤**% នៃអ្នកមានសិទ្ធិបោះឆ្នោតជាយុវជន គិតថាពុំមានឈ្មោះនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត (ពួកគេតាំងនោះពុំបានទៅផ្ទៀងផ្ទាត់ ឬមើលឈ្មោះនៅក្នុងកំឡុងពេលនៃការពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោត) ។

**តារាងទី ៤: មូលហេតុដែលអ្នកមានសិទ្ធិបោះឆ្នោតមិនបានចេញបោះឆ្នោតតាមភេទ និងវ័យ (សំណួរទី២ និង១៦)**

| ល.រ | បញ្ហាផ្សេងៗ | សរុប | | ស្រី | | ប្រុស | | អាយុ ១៨-៣០ឆ្នាំ | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | អត់ដឹង ឬគ្មានព័ត៌មានអំពីការបោះឆ្នោត | ៥២ | ៩,៤% | ២៥ | ៧,១% | ២៧ | ១៣,៤% | ២៦ | ១០,៥% |
| ២ | ខ្ញុំនៅឆ្ងាយពីការិយាល័យបោះឆ្នោត | ១១៨ | ២១,៣% | ៦៧ | ១៩,១% | ៥១ | ២៥,២% | ៥៥ | ២២,៣% |
| ៣ | មិនបានទទួលប័ណ្ណព័ត៌មានបោះឆ្នោត (គេប្រាប់ថាគ្មានសិទ្ធិបើមិនមានប័ណ្ណ) | ៥៣ | ៩,៦% | ៣៩ | ១១,១% | ១៤ | ៦,៩% | ៣០ | ១២,១% |
| ៤ | កន្លែងធ្វើការមិនអនុញ្ញាតអោយទៅបោះឆ្នោត | ១៤ | ២,៥% | ១១ | ៣,១% | ៣ | ១,៥% | ៨ | ៣,២% |
| ៥ | ខ្ញុំអស់ទឹកចិត្ត មិនចង់ទៅបោះឆ្នោត | ២៤ | ៤,៣% | ៩ | ២,៦% | ១៥ | ៧,៤5 | ១១ | ៤,៥% |
| ៦ | មិនអាចដើរទៅបោះឆ្នោតបាន (ឈឺ ចាស់ពេក ឬពិការ) | ១០៨ | ១៩,៥% | ៧៦ | ២១,៧% | ៣២ | ១៥,៨% | ២៧ | ១០,៩% |
| ៧ | ខ្ញុំគិតថាគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ព្រោះខ្ញុំមិនបានទៅពិនិត្យ | ៨៣ | ១៥% | ៥២ | ១៤,៨% | ៣១ | ១៥,៣% | ៤៨ | ១៩,៤% |
| ៨ | រថយន្តឈ្នួលមានតំលៃថ្លៃពេក | ៦ | ១,១% | ៥ | ១,៤% | ១ | ០,៥% | ៤ | ១,៦% |
| ៩ | ផ្សេងៗ | ២៨៨ | ៥២,១% | ១៨៨ | ៥៣,៦% | ១០០ | ៤៩,៥% | ១៣២ | ៥៣,៤% |

## ៧.៤ ឧបសគ្គដែលកើតឡើងនៅការិយាល័យបោះឆ្នោត

**តារាងទី ៥** បានបង្ហាញអោយឃើញថា មានអ្នកបោះឆ្នោតមួយចំនួនបានចេញទៅបោះឆ្នោត ប៉ុន្តែបានជួបឧបសគ្គនៅការិយាល័យបោះឆ្នោត ដែលបណ្តាលអោយពួកគាត់ទាំងនោះពុំបានបោះឆ្នោត។ ក្នុងករណីទាំងនោះ មានចំលើយនៃអ្នកត្រូវសំភាសន៍ ជា: **៣៦,១%** រកឈ្មោះពុំឃើញក្នុងបញ្ជីឈ្មោះបោះឆ្នោត បើទោះបីធ្លាប់បានបោះឆ្នោត ក្នុងការបោះឆ្នោតមុនៗក៏ដោយ។ **២០,១% រកឈ្មោះ ឬការិយាល័យបោះឆ្នោតមិនឃើញ** ព្រោះអត់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត។ **៧,៦%** មិនបានយកប័ណ្ណព័ត៌មាន (VIN) មកជាមួយ ហើយត្រូវបានមន្ត្រីប្រាប់ថា មិនអាចបោះឆ្នោតបាន។ ចំលើយនៃអ្នកបោះឆ្នោត **២,៨%** ត្រូវបាន អាជ្ញាធរ ឬភ្នាក់ងារគណបក្ស នយោបាយរាំងមិនអោយចូលបោះឆ្នោត។ **២,៨%** នៃចំលើយអ្នកបោះឆ្នោតដោយសារមានភាព រញ៉េរញ៉ៃ ឬមានការតំរង់ជួរវែងពេក ដោយពុំមានការអត់ធ្មត់ ក៏ត្រឡប់ទៅផ្ទះវិញ។ ហើយចំលើយនៃអ្នកបោះឆ្នោត **៨,៣%** មិនអាច បោះឆ្នោតបានដោយគាត់ខុសទិន្នន័យ មួយចំនួននៅក្នុងបញ្ជីបោះឆ្នោត។ នៅក្នុងចំណោមអ្នកដែលពុំបានបោះឆ្នោត ក៏មានករណីខ្លះ ដែលកើតឡើងដោយអ្នកបោះឆ្នោត ខ្លួនឯងធ្វើអោយបាត់ឯកសារអត្តសញ្ញាណសំរាប់ការបោះឆ្នោតដែលមាន **៨,៣%**។ **០,៧%** នៃចំលើយអ្នកបោះឆ្នោត បានទៅដល់ ការិយាល័យបោះឆ្នោតហើយតែឈ្មោះរបស់ពួកគាត់ត្រូវបានបោះរួចដោយ អ្នកដទៃ។

**តារាងទី ៥: ឧបសគ្គដែលអ្នកមិនបានបោះឆ្នោតជួបនៅក្នុងការបោះឆ្នោតឆ្នាំ ២០០៨ ( សំនួរទី ៣ និង១៦)**

| ល.រ | បរិយាយបញ្ហា | សរុប | | ស្រី | | ប្រុស | | យុវជន | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) |
| ១ | មិនមានប័ណ្ណព័ត៌មានយកមកជាមួយ មន្ត្រីការិយាល័យឱ្យទៅយកវិញ ទើបបោះឆ្នោតបាន | ១១ | ៧,៦ | ១០ | **១០,៥** | ១ | ២ | ២ | ៣,៥ |
| ២ | មានអាជ្ញាធរ ឬភ្នាក់ងារគណបក្សនយោបាយរារាំងមិនឱ្យចូល | ៤ | ២,៨ | ៣ | ៣,២ | ១ | ២ | ២ | ៣,៥ |
| ៣ | រកឈ្មោះ ការិយាល័យបោះឆ្នោតមិនឃើញព្រោះអត់ប័ណ្ណព័ត៌មាន | ២៩ | **២០,១** | ១៥ | **១៥,៨** | ១៤ | **២៨,៦** | ១១ | **១៩,៣** |
| ៤ | រកឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬការិយាល័យមិនឃើញ ព្រោះគ្មានប័ណ្ណព័ត៌មាន តែធ្លាប់បានបោះឆ្នោតមុនៗដែរនៅក្នុងភូមិនេះ ដូចជាការបោះឆ្នោតឆ្នាំ ២០០៣ និង/ឬ ២០០៧ | ៥២ | **៣៦,១** | ៣១ | **៣២,៦** | ២១ | **៤២,៩** | ២៥ | **៤៣,៩** |
| ៥ | បានទៅដល់ខាងក្នុងការិយាល័យបោះឆ្នោត តែមន្ត្រីការិយាល័យប្រាប់ថា ឈ្មោះខ្លួនត្រូវបានបោះឆ្នោតរួចហើយ | ១ | ០,៧ | ០ | ០ | ១ | ២ | ១ | ១,៨ |
| ៦ | ការិយាល័យបោះឆ្នោតមានភាពរញ៉េរញ៉ៃ, តម្រង់ជួរយូរ ពេកក៏ត្រឡប់ទៅផ្ទះវិញ | ៤ | ២,៨ | ២ | ២,១ | ២ | ៤,១ | ១ | ១,៨ |
| ៧ | មានឯកសារគ្រប់គ្រាន់តែខុសទិន្នន័យ | ១២ | ៨,៣ | ១០ | **១០,៥** | ២ | ៤,១ | ៥ | ៨,៨ |
| ៨ | បាត់ឯកសារបញ្ជាក់អត្តសញ្ញាណ | ១២ | ៨,៣ | ៧ | **៧,៤** | ៥ | ១០,២ | ៥ | ៨,៨ |
| ៩ | ហេតុផលផ្សេង | ៦០ | ៤១,៧ | ៤៦ | ៤៨,៤ | ១៤ | ២៨,៦ | ២១ | ៣៦,៨ |

**តារាងទី ៥** ក៏បង្ហាញអោយឃើញថា ក្នុងចំណោមចំលើយអ្នកបោះឆ្នោតជាស្ត្រីដែលជួបប្រទះបញ្ហានៅកន្លែងបោះឆ្នោត ហើយ មិនបានបោះឆ្នោត មាន **១៥,៨%** រកឈ្មោះ ឬការិយាល័យបោះឆ្នោតមិនឃើញ ដោយសារមិនមានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងមាន **៣២,៦%**ជួបប្រទះបញ្ហាដូចគ្នាដែរ តែពួកគាត់ទាំងនោះធ្លាប់បានបោះឆ្នោតពីមុនៗ។ ចំលើយនៃអ្នកបោះឆ្នោតបុរស ក៏ជួបបញ្ហា ទាំងអស់នេះច្រើនដែរគឺ **២៨.៦%** រកឈ្មោះ ឬការិយាល័យបោះឆ្នោតមិនឃើញ ហើយ៤២.៩% ជួបបញ្ហាដូចនេះដែរ តែពួកគេធ្លាប់បានបោះឆ្នោតមុនៗ។ យ៉ាងណាមិញក្នុងចំណោមចំលើយអ្នកបោះឆ្នោតយុវជនដែលមានអាយុពី (១៨ ទៅ ៣០ឆ្នាំ) បានជួបប្រទះបញ្ហានៅការិយាល័យបោះឆ្នោតដោយរកឈ្មោះ និងការិយាល័យពុំឃើញមានភាគរយសរុប **៦៣,២%** ។

## ៧.៥ ការប្រើប្រាស់ទំរង់ ១០១៨ ក្នុងការបោះឆ្នោតឆ្នាំ ២០០៨

ទំរង់១០១៨ គឺជាឯកសារអត្តសញ្ញាណមួយក្នុងចំណោមឯកសារទាំង១១ ដែលអាចប្រើប្រាស់កំណត់អត្តសញ្ញាណរបស់អ្នកបោះឆ្នោតដើម្បីបោះឆ្នោតនៅការិយាល័យបោះឆ្នោត។ ទំរង់នេះត្រូវបានចេញអោយអ្នកចុះឈ្មោះបោះឆ្នោតទាំងឡាយណាដែលគ្មានឯកសារកំណត់អត្តសញ្ញាណសំរាប់ការបោះឆ្នោត។ នៅក្នុងការផ្ដល់ទំរង់១០១៨ អោយបុគ្គលណាម្នាក់ បុគ្គលនោះត្រូវនាំអ្នកបោះឆ្នោតដែលមានសិទ្ធិស្របច្បាប់ពីរនាក់នៅក្នុងឃុំដែលគាត់រស់នៅមកធានាអះអាងពី អាយុ និងទីលំនៅរបស់បុគ្គលនោះ។

**រូបភាពទី ២: ការប្រើប្រាស់ទំរង់ ១០១៨**




**រូបភាពទី ២** នេះបានបង្ហាញថា នៅក្នុងការបោះឆ្នោតឆ្នាំ២០០៨ មាន **៧.២០%** នៃអ្នកបោះឆ្នោតបានប្រើប្រាស់ទំរង់ ១០១៨ និង៩២.៨០% ទៀតប្រើប្រាស់ឯកសារកំណត់អត្តសញ្ញាណផ្សេងៗទៀត។

## ៧.៦ ប្រភេទឯកសារផ្សេងៗ (ក្រៅពីទម្រង់ ១០១៨) ដែលប្រើប្រាស់ក្នុងពេលបោះឆ្នោត ២០០៨

ក្រៅពីទំរង់១០១៨ ក៏មានឯកសារអត្តសញ្ញាណផ្សេងៗទៀតដែរដែលអាចប្រើប្រាស់សម្រាប់ការបោះឆ្នោត។ ឯកសារទាំងនោះមានៈ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតឆ្លងដែន សៀវភៅគ្រួសារមានរូបថតសាម៉ីខ្លួន ប័ណ្ណសំគាល់ខ្លួនចេញដោយក្រសួង ឬស្ថាប័នរដ្ឋ អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល អត្តសញ្ញាណប័ណ្ណនគរបាលជាតិ អត្តសញ្ញាណប័ណ្ណកងយោធពលខេមរភូមិន្ទ សុទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ ឆាយាគណៈមហានិកាយ និងសង្ឃដីកា។ ការស្រាវជ្រាវនេះ

បានរកឃើញថា អ្នបោះឆ្នោតភាគច្រើនលើសលុបបានប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដើម្បីចូលរួមក្នុងការបោះឆ្នោត ដែលមានរហូតដល់ **៩៦,២០%** នៃអ្នកប្រើប្រាស់ឯកសារផ្សេងៗក្រៅពីទម្រង់១០១៨។

ក្រៅពីការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្នុងការបោះឆ្នោត ក៏មានការប្រើប្រាស់សៀវភៅគ្រួសារមានបិទរូបថតសម៊ីខ្លួនមាន**១,៩%** ប័ណ្ណសំគាល់ខ្លួនចេញដោយក្រសួង ឬស្ថាប័នរដ្ឋមាន **០,១%** អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិលមាន **០,១%** និងឯកសារផ្សេងៗទៀតមាន **១,៦%** ។

**រូបភាពទី ៣: ឯកសារផ្សេងៗ (ក្រៅពីទម្រង់ ១០១៨) ប្រើប្រាស់នៅពេលបោះឆ្នោត (សំណួរទី៤)**




## ៧.៧ មូលហេតុដែលតំរូវអោយមានការប្រើប្រាស់ទំរង់ ១០១៨

នៅក្នុង **រូបភាពទី ៤** បានបងាញអំពីមូលហេតុដែលអ្នកបោះឆ្នោតប្រើប្រាស់ទំរង់១០១៨ ដើម្បីបោះឆ្នោតឆ្នាំ២០០៨ ដែលក្នុងនោះមាន **៧៤,១%** នៃអ្នកប្រើប្រាស់ទំរង់១០១៨ គឺដើម្បីបញ្ជាក់អត្តសញ្ញាណរបស់ពួកគេ ព្រោះអ្នកទាំងនោះគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ។ អ្នកខ្លះទៀតត្រូវការកែតំរូវព័តិមានអោយដូចក្នុងបញ្ជីបោះឆ្នោតផ្លូវការដែលមាន **១១,៣%** និង **១៤,៦%** បានជួបប្រទះបញ្ហាផ្សេងៗទៀត ដូចជាការបាត់បង់ឯកសារសំរាប់ការបោះឆ្នោត។ល។

**រូបភាព ៤: មូលហេតុដែលប្រើប្រាស់ទំរង់ ១០១៨**




## ៧.៨ ការស្ទង់មតិស្តីពីការប្រើប្រាស់ឯកសារបោះឆ្នោតនាពេលអនាគត

**តារាងទី 6** បានបង្ហាញពីមតិអ្នកបោះឆ្នោតក្នុងការប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណសំរាប់ការបោះឆ្នោតនាពេលអនាគតដែលលទ្ធផលបានបង្ហាញអោយឃើញថា មានអ្នកបោះឆ្នោតចំនួន**៧៣%** ពេញចិត្តទៅនឹងការរក្សាទុកការប្រើប្រាស់ឯកសារអត្តសញ្ញាណសម្រាប់បោះឆ្នោតអោយនៅដដែល ខណៈដែល**១៣,៣%** សំណូមពរអោយមានការធ្វើប័ណ្ណបោះឆ្នោតអោយបានច្បាស់ដូចការបោះឆ្នោតឆ្នាំ ១៩៩៨ ហើយ **១៣,៧%** ពុំមានគំនិត ឬយោបល់ទៅលើបញ្ហានេះទេ។

**តារាងទី ៦: មតិក្នុងការប្រើប្រាស់ ឯកសារបញ្ជាក់អត្តសញ្ញាណក្នុងការបោះឆ្នោតនាពេលអនាគត (សំណួរទី៦)**

| ល.រ | មតិអ្នកបោះឆ្នោត | ចំនួន | ភាគរយ (%) |
|---|---|---|---|
| ១ | គួរទុកដដែលដូចពេលបច្ចុប្បន្ន | **៦.២៧២** | **៧៣** |
| ២ | ធ្វើប័ណ្ណបោះឆ្នោតអោយច្បាស់ ដូចការបោះឆ្នោតឆ្នាំ ២០០៨ | **១.១៤២** | **១៣,៣** |
| ៣ | យោបល់ផ្សេងៗ | **១៦៩** | **២** |
| ៤ | មិនដឹង | **១.០០៧** | **១១,៧** |
| | **សរុប** | **៨.៥៩០** | **១០០** |

## ៧.៩ ប័ណ្ណព័ត៌មានបោះឆ្នោត

ដើម្បីជួយសម្រួលឱ្យអ្នកបោះឆ្នោតមានភាពងាយស្រួលនៅក្នុងការស្វែងរកឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោត ប័ណ្ណព័តិមានអ្នកបោះឆ្នោតត្រូវបានចែកឱ្យអ្នកបោះឆ្នោតនៅមុនពេលបោះឆ្នោត។ នៅក្នុង**រូបភាពទី៥** បានបង្ហាញអោយឃើញថា ៩០,៧៤%នៃអ្នកបោះឆ្នោតបានទទួលប័ណ្ណព័តិមានអ្នកបោះឆ្នោត និង**៩,២៦%**ទៀតពុំបានទទួលប័ណ្ណព័តិមានអ្នកបោះឆ្នោតទេ។

**រូបភាពទី ៥: ការចែកចាយប័ណ្ណព័តិមានបោះឆ្នោត**




**តារាងទី ៧: អ្នកដែលមិនបានទទួលប័ណ្ណព័តិមាន និងមិនបានចូលរួមការបោះឆ្នោត ២០០៨ (សំណួរទី១ និង១០)**

| ករណីដែលកើតបញ្ហា | មិនបានចូលរួមការបោះឆ្នោតសភាជាតិ ថ្ងៃទី ២៧ កក្កដា ២០០៨ | | | |
|---|---|---|---|---|
| | ភាគរយសរុប | ប្រុស | ស្រី | អាយុ ១៨-៣០ ឆ្នាំ ) |
| មិនបានទទួលប័ណ្ណព័តិមានបោះឆ្នោត | **៤,៩%** | **៤០,៤%** | **៥៩,៦%** | **៥៦,៧%** |

**តារាងទី ៧** បានបង្ហាញអោយឃើញថា ក្នុងចំណោមអ្នកដែលមិនបានទទួលប័ណ្ណព័តិមានអ្នកបោះឆ្នោត មាន **៤,៩%** ពុំបានចូលរួមក្នុងការបោះឆ្នោតឆ្នាំ២០០៨ ទេ ក្នុងនោះមានស្ត្រីចំនួន **៤០,៤%** បុរសចំនួន **៥៩,៦%** និង **៥៦,៧%** មានវ័យជាយុវជនមានអាយុពី ១៨ ទៅ ៣០ឆ្នាំ។

## ៧.១០ ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

ទាក់ទងទៅនឹងវិធីសាស្ត្រនៃការចែកប័ណ្ណពតិមានបោះឆ្នោត មានអ្នកបោះឆ្នោតមួយភាគធំរហូតដល់**៩២,៦%** នៃអ្នកមានសិទ្ធិបោះឆ្នោតដែលដឹងពីការចែកប័ណ្ណព័តិមានអ្នកបោះឆ្នោតនៅក្នុងភូមិរបស់គាត់ មានការពេញចិត្ត និងគាំទ្រទៅលើដំណើរការនៃការចែកប័ណ្ណព័តិមានអ្នកបោះឆ្នោត ។ ខណៈដែល ៧,៤% ប៉ុណ្ណោះដែលមិនពេញចិត្តទៅនឹងវិធីសាស្ត្រនេះ ។

**រូបភាពទី ៦: ការចែកប័ណ្ណព័តិមានបោះឆ្នោត (សំណួរទី១២)**




**តារាងទី៨** បានបង្ហាញអំពីអនុសាសន៍ផ្តល់ដោយអ្នកមិនពេញចិត្តទៅនឹងវិធីសាស្ត្រក្នុងការចែកចាយប័ណ្ណព័តិមានអ្នកបោះឆ្នោតដើម្បីជួយកែលំអវិធីសាស្ត្រនេះនៅពេលបោះឆ្នោតនាពេលខាងមុខ។ ក្នុងនោះមាន **២២,៤%** សំណូមពរអោយពង្រឹងការងារចែកប័ណ្ណព័តិមានដោយអោយមេភូមិ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាអ្នកទទួលខុសត្រូវ។ **១0%** ចង់អោយមានការផ្លាស់ប្តូររបៀបចែកចាយប័ណ្ណដោយអោយសមាជិកគណបក្សនយោបាយជាអ្នកទទួលខុសត្រូវវិញម្តង និងមាន**៩៣,៩%** សំណូមពរអោយ គ.ជ.ប តែមួយគត់ទទួលខុសត្រូវចែកប័ណ្ណ។

**តារាងទី ៨: អនុសាសន៍ទៅលើការចែកចាយប័ណ្ណព័ត៌មានបោះឆ្នោត**

| ល.រ | អនុសាសន៍ | ចំនួន | ភាគរយ (%) |
|---|---|---|---|
| ១ | គ្រាន់តែពង្រឹងការងារធ្លាប់ធ្វើកន្លងមកដែលមានមេភូមិ និង សមាជិកក្រុមប្រឹក្សាឃុំ , សង្កាត់ ទទួលខុសត្រូវ | **១១៦** | **២២.៤** |
| ២ | ភ្លាស់ប្តូររបៀបចែកចាយអោយទៅសមាជិកគណបក្សនយោបាយ ទទួលខុសត្រូវវិញ | **៥២** | ១០ |
| ៣ | គជប តែមួយគត់ត្រូវទទួលខុសត្រូវ ហើយរៀបចំជ្រើសរើស មនុស្សឯករាជ្យរបស់ខ្លួន | **២៨០** | **៥៣.៩** |
| ៤ | ផ្សេងៗ | **៧១** | **១៣.៧** |
| **សរុប** | | **៥១៩** | ១០០ |

**៧.១១ ការព្រួយបារម្ភរបស់អ្នកបោះឆ្នោត**

អ្នកបោះឆ្នោតបានសំដែងការព្រួយបារម្ភខ្លះដែរក្នុងករណីដែលលទ្ធផលនៃការបោះឆ្នោតបានបញ្ជាក់អោយដឹងថា អ្នករស់នៅក្នុងភូមិ ឃុំ គាំទ្រឱ្យគណបក្សនយោបាយណាមួយ ក្រោយពេលការបោះឆ្នោតរួច។

**តារាងទី ៩: ការព្រួយបារម្ភរបស់អ្នកបោះឆ្នោត (សំណួរទី៨)**

| ល.រ | ការព្រួយបារម្ភ | ចំនួន | ភាគរយ (%) |
|---|---|---|---|
| ១ | ព្រួយបារម្ភខ្លាំងណាស់ | **២៤១** | **២.៨** |
| ២ | ព្រួយបាម្ភខ្លះដែរ | **១៨២១** | **២១.១** |
| ៣ | មិនបារម្ភ | **៥៦៥៤** | **៦៥.៥** |
| ៤ | មិនដឹង | **៩១៤** | **១០.៦** |
| **សរុប** | | ៨៦៣០ | ១០០ |

**តារាងទី ៩** បានបង្ហាញថា **២៣.៩%** នៃអ្នកបានផ្តល់ចម្លើយបានបង្ហាញពីការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ (**២.៨%** បង្ហាញពីការព្រួយបារម្ភខ្លាំង និង **២១.១%** ទៀត មានការព្រួយបារម្ភខ្លះៗ)។ ចំណែកឯ **៦៥.៥%** នៃអ្នកបានផ្តល់ចម្លើយ គាត់ពុំមានការព្រួយបារម្ភអ្វីទាំងអស់។

**រូបភាពទី ៧** បានបង្ហាញថា កត្តាភេទស្រី និងប្រុស មិនមានឥទ្ធិពលទៅលើកំរិតនៃការព្រួយបារម្ភរបស់អ្នកបោះឆ្នោតទេ។ មានន័យថា ចំនួនអ្នកបោះឆ្នោតភេទប្រុស ឬស្រី ដែលបង្ហាញក្តីបារម្ភគឺមានប្រហាក់ប្រហែលគ្នា។

**រូបភាពទី ៧: កំរិតនៃការព្រួយបារម្ភរបស់អ្នកបោះឆ្នោតធៀបនឹងភេទ (សំណួរទី៨ និងទី១៦)**




## ៧.១២ យោបល់អ្នកបោះឆ្នោតចំពោះការផ្ទៀងផ្ទាត់ និងការចុះឈ្មោះបោះឆ្នោត

**រូបភាពទី 8** បានអោយដឹងថា ចំលើយនៃអ្នកបោះឆ្នោតភាគច្រើនគឺ**៨៤,២%** មិនថាប្រុស ឬស្រី ពុំមានអារម្មណ៍ធុញទ្រាន់ នឹងការចុះឈ្មោះ ឬពិនិត្យបញ្ជីឈ្មោះនោះទេ។ មានតែ **១១,៥%**ប៉ុណ្ណោះ ដែលអះអាងថា មានការលំបាក ដោយប្រការផ្សេងៗ ក្នុងនោះមានស្ត្រី **១០,៣៧%** និងបុរស **១៣,២%** ។

**រូបភាពទី ៨: ការលំបាកក្នុងការផ្ទៀតផ្ទាត់ ឬចុះឈ្មោះបោះឆ្នោត (សំណួរទី១៣ និង១៦)**




## ៧.១៣ ភាពមិនប្រក្រតីដែលកើតមានក្នុងកំឡុងពេលនៃការបោះឆ្នោត

**អ្នកផ្តល់បទសម្ភាសន៍ចំនួន៦៩៥** រូប បានបង្ហាញថា ពួកគេ ក្រុមគ្រួសារ ឬមិត្តភ័ក្ត្ររបស់ពួកគេធ្លាប់បានឆ្លងកាត់ភាពមិនប្រក្រតីមួយចំនួនក្នុងកំឡុងពេលបោះឆ្នោតឆ្នាំ២០០៨។

នៅក្នុង **តារាងទី ១០** បង្ហាញពីចម្លើយអ្នកត្រូវសម្ភាសន៍ បញ្ជាក់អោយឃើញថា គាត់ មិត្តភ័ក្ត្ររបស់គាត់ គ្រួសាររបស់គាត់ ឬក៏អ្នកជិតខាងរបស់គាត់បានជួបប្រទះនូវភាពមិនប្រក្រតីនៅក្នុងកំឡុងពេលនៃការបោះឆ្នោតឆ្នាំ២០០៨ កន្លងទៅនេះ។ ករណី ទាំងនោះមានដូចជា ការផ្តល់អំណោយ ឬថវិកាដោយបញ្ជាក់អោយបោះឆ្នោតអោយគណបក្សនយោបាយរបស់ខ្លួនមាន **៦១,៥%** អំពើហឹង្សាប្រឆាំងអ្នកគាំទ្រ ឬសកម្មជនគណបក្សនយោបាយមាន**៥,៣%** ការគំរាមគំហែងមាន**១២,៦%** ការលប់ ឈ្មោះអ្នកបោះឆ្នោតមាន**២៩,២%** ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយលំអៀងមាន**១៤,៣%** គ្មានការសំងាត់នៅពេលបោះឆ្នោត **៣,៦%** និងមានការបង្ខំអោយអ្នកបោះឆ្នោតស្បថឱ្យបោះឆ្នោតជូនគណបក្សខ្លួនមាន**៧,៩%** និងករណីមួយចំនួនផ្សេងទៀត មាន ២១.៣%។

**តារាងទី ១០: ភាពមិនប្រក្រតីដែលអ្នកបោះឆ្នោតបានជួបប្រទះក្នុងការបោះឆ្នោតឆ្នាំ២០០៨ (សំណួរទី៩)**

| លរ | ករណីដែលជួបប្រទះ | ចំលើយ | ភាគរយ (%) |
|---|---|---|---|
| ១ | អោយអំណោយ ឬថវិកាដោយបញ្ជាក់ថាបោះឆ្នោត អោយគណបក្សណាមួយ | ៤៣០ | ៦១,៥% |
| ២ | ហឹង្សាប្រឆាំងអ្នកគាំទ្រ ឬសកម្មជនគណបក្ស | ៣៧ | ៥,៣% |
| ៣ | ការគំរាមកំហែង | ៨៨ | ១២,៦% |
| ៤ | លុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជី | ២០៤ | ២៩,២% |
| ៥ | ប្រព័ន្ធផ្សព្វផ្សាយលំអៀង | ១០០ | ១៤,៣% |
| ៦ | គ្មានការសំងាត់ក្នុងការគូសសន្លឹកឆ្នោត | ២៥ | ៣,៦% |
| ៧ | បង្ខំអោយស្បថបោះឆ្នោតអោយគណបក្សណាមួយ | ៥៥ | ៧,៩% |
| ៨ | បន្លំសន្លឹកឆ្នោត | ១១ | ១,៦% |
| ៩ | ផ្សេងៗ | ១៤៩ | ២១,៣% |

## ៧.១៤ ការផ្ទៀងផ្ទាត់ព័ត៌មានអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០០៨

ការផ្ទៀងផ្ទាត់ឯកសារអត្តសញ្ញាណអ្នកបោះឆ្នោតនេះ គឺសំដៅទៅលើការធ្វើសវនកម្មផ្ទៀងផ្ទាត់ទិន្នន័យរបស់អ្នកបោះឆ្នោតដែលមាននៅក្នុងឯកសារអត្តសញ្ញាណប្រើប្រាស់ក្នុងការបោះឆ្នោតឆ្នាំ២០០៨ និងទិន្នន័យដែលមាននៅក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០០៨។ ទិន្នន័យដែលត្រូវផ្ទៀងផ្ទាត់មានចំនួន៤ គឺ "ឈ្មោះអ្នកបោះឆ្នោត" "ថ្ងៃ ខែ ឆ្នាំកំណើត" "ភេទ" និង "អាសយដ្ឋាន (ឃុំ និងខេត្ត)"។ នៅក្នុង**តារាង១១** បានបង្ហាញអោយឃើញថា ភាពត្រឹមត្រូវនៅក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០០៨ មានត្រឹមតែ**៥៩,៧%** ហើយក្នុងតារាងនេះផងដែរក៏មានអ្នកបោះឆ្នោត**២១,៨%** មានខុសព័តិមានយ៉ាងតិចមួយករណីពីបញ្ជីបោះឆ្នោតផ្លូវការ២០០៨ ។ យើងក៏រកឃើញផងដែរថា មាន**១៨,៥០%** (**១៦,៣%** បានបោះឆ្នោតនៅឆ្នាំ២០០៧ និង/ឬ ២០០៨ និង**២,២%** ជាអ្នកមានសិទ្ធិបោះឆ្នោតទើបចុះឈ្មោះថ្មី) មិនមានព័តិមាន/ទិន្នន័យណាមួយ (ឈ្មោះ ភេទ អាយុ អស័យដ្ឋាន) នៅក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០០៨ ទេ។

ករណីទាំងនេះកើតឡើងដោយសារៈ

១. អ្នកបោះឆ្នោតពុំបានទៅធ្វើបច្ចុប្បន្នភាពអស័យដ្ឋានរបស់ខ្លួន បន្ទាប់ពីផ្លាស់ទីលំនៅដែលជាហេតុនាំឱ្យខុសអស័យដ្ឋាន ឬមិនមានទិន្នន័យក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០០៨

២. អ្នកបោះឆ្នោតមិនបានទៅផ្ទៀងផ្ទាត់ព័តិមានរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ។

៣. ប្រតិបត្តិការរបស់ គ.ជ.ប និងការគ្រប់គ្រងទិន្នន័យក្នុងកុំព្យូទ័រមានបញ្ហាទាក់ទងនិងការគ្រប់គ្រងគុណភាព។

៤. ស្មៀនឃុំបំពេញព័ត៌មានខុស ហើយបញ្ជូនព័ត៌មានខុសនេះទៅអោយ គ.ជ.ប ។

៥. ការភាន់ច្រឡំរវាង គ.ជ.ប និងក្រុមប្រឹក្សាឃុំ/សង្កាត់ (ក្រុមប្រឹក្សាឃុំ/សង្កាត់ស្ថិតនៅក្រោមការណែនាំពីក្រសួងមហាផ្ទៃ) ទាក់ទងការងារ បោះឆ្នោត ។

**តារាង ១១: ការផ្ទៀងផ្ទាត់ឯកសារអត្តសញ្ញាណអ្នកបោះឆ្នោតក្នុងបញ្ជីឈ្មោះផ្លូវការ ២០០៨ (សំនួរទី ១៦)**

| ល.រ | គុណភាពបញ្ជីបោះឆ្នោត | ឈ្មោះ | ថ្ងៃខែឆ្នាំ | ភេទ | អាសយដ្ឋាន (ខេត្ត និងឃុំ) | ភាគរយអ្នកផ្តល់ចម្លើយ | ភាគរយអ្នកផ្តល់ចម្លើយ (មិនបានផ្ទៀងផ្ទាត់ជាមួយអាសយដ្ឋាន) |
|---|---|---|---|---|---|---|---|
| ១ | ភាពត្រឹមត្រូវ | ៧៣% | ៦៦,៤០% | ៧៧,៩០% | ៧៤,៦០% | ៥៩,៧០% | ៦៣,៤០% |
| ២ | ភាពមិនត្រឹមត្រូវ | ៧,២០ | ១៣,៨០% | ០,៤០% | ៥,៦០% | ២១,៨០% | ១៨,១% |
| ៣ | គ្មានព័ត៌មានក្នុងបញ្ជីឈ្មោះបោះឆ្នោត ២០០៨ | | | ១៨,៥០% (ដែល ១៦,៣% បានបោះឆ្នោតក្នុង ឆ្នាំ ២០០៧ និង ២០០៨ និង ២,២% ជាអ្នកមានសិទ្ធិបោះឆ្នោតថ្មី) | | | |

## ៨. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្ហាញឱ្យឃើញពីចំនុចវិជ្ជមាន និងចំនុចដ៏គួរឱ្យព្រួយបារម្ភមួយចំនួន ។

នៅក្នុងឆ្នាំ២០០៨ ចំនួនអ្នកដែលបានចូលរួមក្នុងការបោះឆ្នោតមានការកើនឡើង ព្រោះហេតុថាមានការកើនឡើងនៃប្រជាជនក្នុងប្រទេស ក៏ប៉ុន្តែភាគរយនៃអ្នកបានបោះឆ្នោតមានការថយចុះពី៨៣% នៅក្នុងឆ្នាំ ២០០៣ ទៅ៧៥% នៅក្នុងឆ្នាំ ២០០៨ ។ ទាំងនេះបណ្តាលអោយមានការព្រួយបារម្ភដោយសារមានប្រជាជនប្រហែល៤៤០.០០០នាក់ ដែលមានសិទ្ធិបោះឆ្នោត (ភាគច្រើននៃអ្នកទាំងនេះបានបោះឆ្នោតនៅក្នុងឆ្នាំ២០០៣ និង២០០៧) ពុំបានបោះឆ្នោតដោយសារបញ្ហាផ្សេងៗ ដែលច្រើនតែជាករណីដែលអ្នកបោះឆ្នោតពុំអាចរកឈ្មោះ ឬការិយាល័យបោះឆ្នោតឃើញ ។ ទោះបីយ៉ាងណា បើសិនជាបញ្ជីបោះឆ្នោតឆ្នាំ២០០៨ មិនមានភាពត្រឹមត្រូវ១០០%ទេ នោះចំនួននេះអាចតិចជាងនេះ ដោយសារតែមានឈ្មោះខ្មោច ឬ/និង ឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០០៧ ។

អ្នកបោះឆ្នោតភាគច្រើនមានការពេញចិត្តទៅនឹងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ ឬឯកសារដូចបច្ចុប្បន្នសំរាប់ការបោះឆ្នោត ហើយភាគច្រើននៃប្រជាពលរដ្ឋបានប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។ មានអ្នកបានចុះឈ្មោះបោះឆ្នោតប្រហែល ៤៤០.០០០នាក់ បានប្រើប្រាស់ទំរង់១០១៨ សំរាប់ការបោះឆ្នោតឆ្នាំ២០០៨ (បើយើងទាញយកតួលេខរកឃើញតំណាងទូទាំងប្រទេស) ។

អ្នកបោះឆ្នោតភាគច្រើនបានទទួលប័ណ្ណពត៌មានបោះឆ្នោត ហើយមានការពេញចិត្តទៅនឹងការចែកចាយប័ណ្ណពត៌មាននេះ ប៉ុន្តែក៏មានអ្នកបោះឆ្នោតខ្លះពុំបានទទួលប័ណ្ណពត៌មានបោះឆ្នោតនេះដែរ។ ក្នុងចំណោមអ្នកដែលមិនពេញចិត្ត បានផ្តល់យោបល់ថា គ.ជ.ប ត្រូវតែទទួលខុសត្រូវចំពោះការចែកចាយនេះនៅពេលបោះឆ្នោតនាអនាគត ។

រដ្ឋបាលរបស់រដ្ឋ និងអាជ្ញាធរនៅតាមតំបន់ខ្វះអព្យាក្រឹតភាព ហើយមានក៏មានការកើនឡើងនូវការទិញសន្លឹកឆ្នោត និងការចែកអំណោយ។ មានអ្នកបំរើការងាររដ្ឋ អាជ្ញាធរតាមតំបន់ កំលាំងប្រដាប់អាវុធមួយចំនួនបានធ្វើសកម្មភាពចូលរួមការចែកអំណោយដល់ប្រជាពលរដ្ឋ។

អ្នកបោះឆ្នោតភាគច្រើនពុំមានការធុញទ្រាន់ចំពោះនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត ឬការផ្ទៀងផ្ទាត់ឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតទេ។ ក៏ប៉ុន្តែ វាហាក់ដូចជាអ្នកបោះឆ្នោតភាគច្រើនពុំបានទៅផ្ទៀងផ្ទាត់ឈ្មោះរបស់ពួកគេនៅក្នុងបញ្ជីបោះឆ្នោតទេ ព្រោះលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញអោយឃើញថា ភាពត្រឹមត្រូវនៃព័ត៌មានអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ២០០៨ មានត្រឹមតែ ៦៣% ប៉ុណ្ណោះ មានន័យថាទិន្នន័យអ្នកបោះឆ្នោត (ឈ្មោះ ឆ្នាំកំណើត និងភេទ) ដូចបញ្ជីបោះឆ្នោត ហើយនឹងមិនបាត់បង់សិទ្ធិបោះឆ្នោតឡើយ។

# ឧបសម្ព័ន្ធ ១: វិធីសាស្ត្រនៃការស្រាវជ្រាវ

## ១. វិធីសាស្ត្រក្នុងការកំណត់ចំនួនការិយាល័យបោះឆ្នោតសំណាក និង ទំហំនៃការអង្កេត

វិធីសាស្ត្រនៃការជ្រើសរើសសំណាក គឺយើងផ្តោតតាមវិធីសាស្ត្ររើសការិយាល័យបោះឆ្នោតដែលអនុវត្តក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ ២០០៨ ក្នុង ២៤ខេត្ត/ក្រុង។

**ជំហានទី ១:**

ការជ្រើសរើសសំណាក យើងបានកំណត់យកមណ្ឌលចំនួន២៤ ខេត្ត/ក្រុង ដើម្បីធ្វើកិច្ចការងារនេះ។ ដោយយោងលើការសិក្សាតាមលក្ខណៈបច្ចេកទេសស្ថិតិ យើងត្រូវការប្រើប្រាស់ការិយាល័យបោះឆ្នោតគោលដៅចំនួន**៧៧០** ក្នុងចំណោម **១៥២៥៤** ការិយាល័យបោះឆ្នោត ទូទាំងប្រទេស។

**ជំហានទី ២:**

សិក្សារកចំនួនអ្នកត្រូវធ្វើការសម្ភាសន៍សមស្របមួយសំរាប់ការវាយតំលៃពតិមានតាមមណ្ឌលនីមួយៗ។ ក្នុងករណីនេះ យើងអាចគណនាតាមវិធីសាស្ត្របច្ចេកទេស (Method of Statistic) ដោយ កំណត់យកកំរិតជឿជាក់ (Confidence level) នៃការវាយតំលៃ ៩៥% ក្នុងកំរិតលំអៀង (Margin of error) ៥% ។ រូបមន្តសំរាប់ធ្វើការវាយ តំលៃមានដូចខាងក្រោម:

$$n = \frac{NZ_{\alpha/2}^2}{4(N-1)E^2 + Z_{\alpha/2}^2}$$

| **កំណត់សំគាល់** | |
|---|---|
| n | ចំនួនអ្នកដែលត្រូវសម្ភាសន៍ តាមមណ្ឌលនីមួយៗ (Sample Size) |
| N | ចំនួនអ្នកបោះឆ្នោតសរុបតាមមណ្ឌលបោះឆ្នោតនីមួយៗ (Population size) |
| E | កំរិតលំអៀង (Margin of error) ៥% |
| $Z_{\alpha/2}^2$ | មេគុណនៃរបាយទិន្នន័យណ័រម៉ាល់ (Coefficient of Normal Distribution) |

តារាងខាងក្រោមជា ចំនួនអ្នកត្រូវធ្វើការសម្ភាសន៍ ដែលទទួលបានពីវិធីសាស្ត្រនៃការគណនា ដូចខាងលើៈ

**បំណែងចែក ទំហំសំណាក នៅតាមខេត្ត ក្រុង នីមួយៗ**

| ល.រ | ឈ្មោះខេត្ត ក្រុង | ចំនួនការិយាល័យបោះឆ្នោត | ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត | ចំនួនអ្នកបោះឆ្នោតដែលត្រូវសម្ភាសន៍ (n) |
|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ៤០ | ២០១០៨ | ៣៧៧ |
| ២ | បាត់ដំបង | ៥៣ | ៣០៣៩៩ | ៣៨០ |
| ៣ | កំពង់ចាម | ១០៩ | ៥៤១០៨ | ៣៨១ |
| ៤ | កំពង់ឆ្នាំង | ២៨ | ១៤៣៤៣ | ៣៧៤ |
| ៥ | កំពង់ស្ពឺ | ៤១ | ២១២៩៧ | ៣៧៧ |
| ៦ | កំពង់ធំ | ៣៧ | ១៩០៧៩ | ៣៧៧ |
| ៧ | កំពត | ៣២ | ១៨៥៨៧ | ៣៧៦ |
| ៨ | កណ្តាល | ៦៩ | ៤០១៨៨ | ៣៨១ |
| ៩ | កោះកុង | ៩ | ៤១៦១ | ៣៥២ |
| ១០ | ក្រចេះ | ១៧ | ៩៧៧៣ | ៣៧០ |
| ១១ | មណ្ឌលគិរី | ៤ | ១៦៣៤ | ៣១១ |
| ១២ | ភ្នំពេញ | ៦៤ | ៣៦៩១៨ | ៣៨០ |
| ១៣ | ព្រះវិហារ | ៨ | ៣៦៨០ | ៣៤៨ |
| ១៤ | ព្រៃវែង | ៦៩ | ៣៧០០៩ | ៣៨០ |
| ១៥ | ពោធិសាត់ | ២៣ | ១០៦៧១ | ៣៧១ |
| ១៦ | រតនះគិរី | ៧ | ៣៥៧៧ | ៣៤៧ |
| ១៧ | សៀមរាប | ៤៤ | ២២៤២៧ | ៣៧៨ |
| ១៨ | កំពង់សោម | ១០ | ៥២០៩ | ៣៥៨ |
| ១៩ | ស្ទឹងត្រែង | ៦ | ២៨៣៨ | ៣៣៨ |
| ២០ | ស្វាយរៀង | ៣៣ | ១៩០៩០ | ៣៧៧ |
| ២១ | តាកែវ | ៥៣ | ២៩៥២៤ | ៣៨០ |
| ២២ | ឧត្តរមានជ័យ | ៩ | ៤៨៧៩ | ៣៥៦ |
| ២៣ | ក្រុងកែប | ២ | ១២៤០ | ២៩៣ |
| ២៤ | ប៉ៃលិន | ៣ | ១៧៧៣ | ៣១៦ |
| **សរុប** | | **៧៧០** | **៤១២៥១២** | **៨៦៧៨** |

## ២. វិធីសាស្ត្រនៃការជ្រើសរើសការិយាល័យសំណាក នៅតាមខេត្ត ក្រុងនីមួយៗ

ដោយដឹងចំនួនអ្នកបោះឆ្នោតនៅក្នុងខេត្ត/ក្រុងនីមួយៗ ដែលត្រូវយកសំរាប់ការធ្វើបទសម្ភាសន៏ តាមការគណនាតាមរូបមន្តខាងលើ ក្នុងករណីនេះយើងត្រូវដឹងថា តើអ្នកបោះឆ្នោតទាំងនោះត្រូវជ្រើសរើសចេញពីក្នុង ឃុំ/សង្កាត់ ឬក៏ការិយាល័យបោះឆ្នោតណាខ្លះ ក្នុងគ្រប់ស្រុកទាំងអស់ទូទាំងប្រទេស? ក្នុងការដោះស្រាយបញ្ហានេះ យើងប្រើវិធីសាស្ត្រស្ថិតិមួយ ដែលអោយឈ្មោះថា "Stratified sampling" ។

**ការជ្រើសរើសការិយាល័យបោះឆ្នោតសំណាកតាមមណ្ឌលនីមួយៗ**

ក្រោយពីទទួលបានចំនួនអ្នកត្រូវសំម្ភាសន៏សរុប ដែលជាសំណាកតាមមណ្ឌលនីមួយៗ ដែលជាតំណាង ខេត្ត/ក្រុង រួចយើងប្រើប្រាស់វិធីសាស្ត្រ "Stratified Sampling Method" ដើម្បីរកចំនួនការិយាល័យបោះឆ្នោត ទៅតាមឃុំ/សង្កាត់ក្នុងមណ្ឌលនិមួយៗ រួចប្រើវិធីសាស្ត្រដដែលនេះ កំណត់រកអ្នកដែលត្រូវសម្ភាសន៏ ក្នុងការិយាល័យនីមួយៗ។ ការបែងចែកនេះអាស្រ័យទៅលើប្រជាពលរដ្ឋ ដែលបានចុះឈ្មោះតាមការិយាល័យនីមួយៗ (strata) ។

ខាងក្រោមនេះ ជារូបមន្តសំរាប់ស្វែងរកចំនួនអ្នកបោះឆ្នោត តាមការិយាល័យក្នុងខេត្តក្រុងនីមួយៗ សមាមាត្រ ទៅនឹងចំនួនអ្នកបានចុះឈ្មោះបោះឆ្នោត ២០០៨ ។

$$\mathbf{n_i} = n^* P_i \text{ , ( i=1,2,3,…,14)}$$

**ni** ជាចំនួនអ្នកត្រូវសម្ភាសន៏ក្នុងការិយាល័យសំណាកនីមួយៗ ដែលទទួលបានតាមតំលៃសមាមាត្រ **Pi**

**n** ជាចំនួនអ្នកបោះឆ្នោតសរុបក្នុងការិយាល័យសំណាកនីមួយៗ

**Pi** ជាតំលៃសមាមាត្រនៃអ្នកមានឈ្មោះបោះឆ្នោតក្នុងការិយាល័យសំណាកតាមខេត្តក្រុងនីមួយៗ

**ចំណាំ:** Pi ជាតំលៃមួយដែលយើងប្រើប្រាស់រូបមន្ត Proportion សំរាប់ការរកតំលៃសមាមាត្រ តាមការិយាល័យក្នុងខេត្តក្រុងនីមួយៗ។ ខាងក្រោមជារូបមន្ត ដើម្បីគណនា:

$$\mathbf{P_i = N_i / N}$$

**Ni** ជាចំនួនអ្នកបានចុះឈ្មោះបោះឆ្នោតសរុបតាមការិយាល័យសំណាកនីមួយៗក្នុងខេត្ត / ក្រុងនីមួយៗ

**N** ជាចំនួនអ្នកបោះឆ្នោតសរុបក្នុងខេត្ត / ក្រុង នីមួយៗ

ដើម្បីឃើញព័ត៌មានលំអិតក្នុងការិយាល័យសំណាកតាមមណ្ឌលនីមួយៗ សូមពិនិត្យមើលលើតារាងលំអិត បានភ្ជាប់មកជាមួយ ដូចខាងក្រោម:

## បំណែងចែក ឃុំនិងការិយាល័យបោះឆ្នោតសំណាកនៅតាមស្រុក និងខេត្ត ក្រុង នីមួយៗ

| ល.រ | ឈ្មោះខេត្ត/ក្រុង | ស្រុក/ខ័ណ្ឌ | ឃុំ/សង្កាត់ (sample) | ការិយាល័យបោះឆ្នោត (Sample) | ចំនួនអ្នកបោះឆ្នោត ក្នុងបញ្ជី បោះឆ្នោត | ចំនួនអ្នកបោះឆ្នោត ដែល ត្រូវសម្ភាសន៍ |
|---|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ៨ | ២៦ | ៤០ | ២០១០៨ | ៣៧៧ |
| ២ | បាត់ដំបង | ១២ | ៤០ | ៥៣ | ៣០៣៩៩ | ៣៨០ |
| ៣ | កំពង់ចាម | ១៦ | ៨២ | ១០៩ | ៥៤១០៨ | ៣៨១ |
| ៤ | កំពង់ឆ្នាំង | ៧ | ២៥ | ២៨ | ១៤៣៤៣ | ៣៧៤ |
| ៥ | កំពង់ស្ពឺ | ៨ | ៣១ | ៤១ | ២១២៩៧ | ៣៧៧ |
| ៦ | កំពង់ធំ | ៨ | ៣២ | ៣៧ | ១៩០៧៩ | ៣៧៧ |
| ៧ | កំពត | ៨ | ២៧ | ៣២ | ១៨៥៨៧ | ៣៧៦ |
| ៨ | កណ្តាល | ១១ | ៥៧ | ៦៩ | ៤០១៨៨ | ៣៨១ |
| ៩ | កោះកុង | ៧ | ៨ | ៩ | ៤១៦១ | ៣៥២ |
| ១០ | ក្រចេះ | ៥ | ១៣ | ១៧ | ៩៧៧៣ | ៣៧០ |
| ១១ | មណ្ឌលគិរី | ២ | ៤ | ៤ | ១៦៣៤ | ៣១១ |
| ១២ | ភ្នំពេញ | ៧ | ៤២ | ៦៤ | ៣៦៩១៨ | ៣៨០ |
| ១៣ | ព្រះវិហារ | ៦ | ៨ | ៨ | ៣៦៨០ | ៣៤៨ |
| ១៤ | ព្រៃវែង | ១២ | ៥៥ | ៦៩ | ៣៧០០៩ | ៣៨០ |
| ១៥ | ពោធិសាត់ | ៥ | ២០ | ២៣ | ១០៦៧១ | ៣៧១ |
| ១៦ | រតនះគិរី | ៤ | ៧ | ៧ | ៣៥៧៧ | ៣៤៧ |
| ១៧ | សៀមរាប | ៩ | ៣១ | ៤៤ | ២២៤២៧ | ៣៧៨ |
| ១៨ | កំពង់សោម | ៣ | ៦ | ១០ | ៥២០៩ | ៣៥៨ |
| ១៩ | ស្ទឹងត្រែង | ៣ | ៦ | ៦ | ២៨៣៨ | ៣៣៨ |
| ២០ | ស្វាយរៀង | ៧ | ២៤ | ៣៣ | ១៩០៩០ | ៣៧៧ |
| ២១ | តាកែវ | ១០ | ៣៦ | ៥៣ | ២៩៥២៤ | ៣៨០ |
| ២២ | ឧត្តរមានជ័យ | ៤ | ៨ | ៩ | ៤៨៧៩ | ៣៥៦ |
| ២៣ | ក្រុងកែប | ២ | ២ | ២ | ១២៤០ | ២៩៣ |
| ២៤ | ប៉ៃលិន | ២ | ៣ | ៣ | ១៧៧៣ | ៣១៦ |
| **សរុប** | | **១៦៦** | **៥៩៣** | **៧៧០** | **៤១២៥១២** | **៨៦៧៨** |

# វិធីសាស្ត្រក្នុងការសម្ភាសន៍

នៅក្នុងការធ្វើសម្ភាសន៍ គេកំណត់យកចំនួនអ្នកមានសិទ្ធិបោះឆ្នោត ទៅតាមទំហំដែលបានកំណត់ក្នុងភូមិនីមួយៗ ដែលគណនាតាមវិធីសាស្ត្រ ខាងលើ និងគោរពតាមគោលការណ៍មួយ ច្បាស់លាស់។ សំរាប់វិធីសាស្ត្រក្នុងការ ជ្រើសរើសនេះ ខុមហ្វ្រែល បានប្រើប្រាស់វិធីសាស្ត្រមួយ ដែលហៅថា ការជ្រើសរើសដោយបង្កើត**ប្រព័ន្ធចៃដន្យ** (Systematic Sampling Method) ។

**ការកំណត់ ផ្ទះនីមួយៗដែលជាគោលដៅសំរាប់ការសម្ភាសន៍**

ដើម្បីកំណត់យកផ្ទះដែលត្រូវសំភាសន៍នីមួយៗ វាអាស្រ័យលើចំនួនផ្ទះ (មួយផ្ទះមួយគ្រួសារ) ដែលមាននៅក្នុងភូមិនីមួយៗ។ ដូច្នេះ ដើម្បីជ្រើសរើសយកគ្រួសារតាមផ្ទះនីមួយៗមកធ្វើការសម្ភាសន៍ ជាដំបូងអ្នកចុះធ្វើបទសម្ភាសន៍ត្រូវតែជួបជាមួយមេភូមិ ឬសមាជិកភូមិណាមួយដើម្បីកំណត់អោយបានច្បាស់ពីចំនួនគ្រួសារនៅក្នុងភូមិនេះ។ បន្ទាប់ មកអ្នកធ្វើបទសម្ភាសន៍ត្រូវដឹងថា តើភូមិនេះត្រូវការជ្រើសរើសមនុស្សសម្ភាសន៍ប៉ុន្មាននាក់? ។ ក្នុងករណីមានព័ត៌មានទាំងអស់នេះហើយ អ្នកធ្វើបទសម្ភាសន៍ត្រូវកំណត់រកចន្លោះនៃការជ្រើសរើស (Interval scale) ដូចខាងក្រោម:

$$\text{Interval Scale (Int)} = \frac{N_i}{n_i}$$

Ni ជាចំនួនផ្ទះសរុបក្នុងភូមិ

ni ជាចំនួនអ្នកត្រូវធ្វើការសម្ភាសន៍

**ឧទាហរណ៍:**

នៅក្នុងភូមិនេះមានចំនួន **៥០គ្រួសារ** ម្យ៉ាងទៀត ក្នុងភូមិនេះត្រូវការសម្ភាសន៍ **៥នាក់** ដូចនេះការកំណត់រកចន្លោះនៃការជ្រើសរើស (Interval scale) ស្មើនឹង ៥០/៥ =១០ មានន័យថារាប់ពីចំណុចទី១ រហូតបាន ១០ផ្ទះ យកផ្ទះមួយដែលជាលេខរៀងទី១០ មកសម្ភាសន៍ បន្ទាប់មករាប់ ១០ផ្ទះបន្តទៀត ។

**ការជ្រើសរើសផ្ទះដើម្បីចូលសម្ភាសន៍ដំបូង**

ដើម្បីជ្រើសរើសផ្ទះដំបូង អ្នកចុះធ្វើការសម្ភាសន៍ ត្រូវប្រើវិធីសាស្ត្រចាប់ឆ្នោតដោយចៃដន្យ (Lottery Method) ដែលកំណត់យក ១០សន្លឹក ដែលមានពីលេខ១ ដល់១០។ នៅក្នុងករណីចាប់បានលេខណាមួយ អ្នកសម្ភាសន៍ត្រូវរាប់ផ្ទះពីទីតាំងដំបូងគេ ហើយផ្តើមអង្កេតពីទីតាំងផ្ទះដែលជាលេខដែលគាត់ចាប់បាន ហើយចាត់ទុកថាជាផ្ទះទីមួយ។ ផ្ទះដែលត្រូវសំភាសន៍បន្តទៀតគឺជាទីតាំងផ្ទះដែលត្រូវជ្រើសរើសដោយរំលងទៅតាមតំលៃចន្លោះ(Interval scale) ដែលបានកំណត់ ។

**ការជ្រើសរើសសមាជិកគ្រួសារដើម្បីសម្ភាសន៍**

ជាដំបូងនៅពេលចូលដល់គ្រួសារដែលត្រូវធ្វើការសម្ភាសន៍ អ្នកធ្វើបទសម្ភាសន៍ត្រូវស្រង់ឈ្មោះសមាជិកគ្រួសារដែលមានអាយុចាប់ពី១៨ឆ្នាំ (គិតត្រឹមថ្ងៃបោះឆ្នោតថ្ងៃទី ២៧ កក្កដា ២០០៨) ឡើងទៅ ហើយកត់ត្រាចូលទៅក្នុងតារាងបញ្ជី។

បន្ទាប់មកអ្នកសម្ភាសន៍ត្រូវកំណត់យកឈ្មោះណាដែលមានព្យញ្ជនៈលំដាប់ដើមគេមកធ្វើបទសម្ភាសន៍ តែប្រសិនចបើព្យញ្ជនៈទី១ នៃឈ្មោះអ្នកត្រូវសម្ភាសន៍ដូចគ្នា អ្នកសម្ភាសន៍ត្រូវមើលបន្តទៅស្រះ ឬព្យញ្ជនៈទី២ ទៀត។

**ឧទាហរណ៍ដែលពន្យល់ក្នុងការជ្រើសរើសអ្នកសម្ភាសន៍**

សន្មតថានៅក្នុងភូមិ "**ក**" មួយមានផ្ទះចំនួន ៦០ ខ្នង។ ក្នុងភូមិនេះចំនួនអ្នកត្រូវសម្ភាសន៍ត្រូវបានកំណត់យក ១០ នាក់ តាមលក្ខណៈបច្ចេកទេសស្ថិតិ។

ដើម្បីជ្រើសរើសបានអ្នកដែលត្រូវសម្ភាសន៍ យើងត្រូវអនុវត្តជាជំហាន៧ ដូចខាងក្រោម:

- ជំហានទី១: ជាដំបូងយើងត្រូវគណនារកចន្លោះនៃការជ្រើសរើស ៦០ផ្ទះ/១០នាក់= ៦ផ្ទះ
- ជំហានទី២: យើងធ្វើសន្លឹកឆ្នោតចំនួន ៦សន្លឹក ដែលសន្លឹកនីមួយៗ មានពីលេខ១ រហូតដល់លេខ៦ ហើយជ្រើសរើសសន្លឹកឆ្នោតដោយចៃដន្យ ចំនួន ១សន្លឹក។ ក្នុងករណីនេះសន្មតថា យើងចាប់បានសន្លឹកឆ្នោតលេខ ៣។
- ជំហានទី៣: ត្រូវជ្រើសរើសផ្ទះទី៣ នៅដើមភូមិដែលកំណត់ថា ជាផ្ទះទី ១ដែលត្រូវចូលសម្ភាសន៍
- ជំហានទី៤: ត្រូវស្រង់ឈ្មោះសមាជិកគ្រួសារដែលមានអាយុ១៨ឆ្នាំ ឡើងទៅចូលក្នុងបញ្ជីឈ្មោះរបស់ អ្នកសម្ភាសន៍ ដូចជាឧទាហរណ៍ក្នុងតារាងខាងក្រោម:

| ល.រ | ឈ្មោះសមាជិកគ្រួសារ | ភេទ | អាយុ | អ្នកត្រូវសម្ភាសន៍ | មានវត្តមាន |
|---|---|---|---|---|---|
| ១ | បុប្ផា | ស្រី | ២០ | ☑ | ☑ |
| ២ | តារា | ប្រុស | ៣០ | ☐ | ☐ |
| ៣ | ចាន់នី | ស្រី | ២២ | ☐ | ☑ |

ក្នុងករណីនេះ អ្នកដែលត្រូវសម្ភាសក្នុងផ្ទះនេះ គឺ **ចាន់នី** ។

## ឧបសម្ព័ន្ធ ២: កម្រងសំនួរសំរាប់ការអង្កេត

ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌នៅកម្ពុជា**

**សមាគមជាមួយ KYA, NICFEC និង PDP-Center**

# ទំរង់ស្រាវជ្រាវបញ្ហាទាក់ទិននឹងអ្នកបោះឆ្នោត

| | | | |
|---|---|---|---|
| ឈ្មោះអ្នកទៅសម្ភាសន៍: | | ហត្ថលេខាអ្នកទៅសម្ភាសន៍: | |
| ទីតាំងអ្នកត្រូវសម្ភាសន៍ ភូមិ: | | ឃុំ_សង្កាត់: | |
| ស្រុក_ខណ្ឌ: | | ខេត្ត_រាជធានី: | |
| ថ្ងៃ/ខែ/ឆ្នាំ បំពេញទម្រង់: | ថ្ងៃ ខែ ឆ្នាំ ២០០៩ | ពេលវេលាចាប់ផ្តើម និងបញ្ចប់: | |
| ឈ្មោះប្រធានក្រុមការងារ: | | ហត្ថលេខាប្រធានក្រុមការងារ: | |
| ឈ្មោះអ្នកត្រួតពិនិត្យថ្នាក់ខេត្ត: | | ហត្ថលេខាអ្នកត្រួតពិនិត្យថ្នាក់ខេត្ត: | |

**១-តើអ្នកបានបោះឆ្នោត នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៨ កន្លងទៅនេះ ដែរឬទេ?**

☐ បានបោះឆ្នោត (រំលងសំនួរលេខ ២ និងលេខ ៣)		☐ មិនបានបោះឆ្នោតទេ (ជ្រើសរើសមូលហេតុខាងក្រោម)

| | | | |
|---|---|---|---|
| ☐ | មិនបានទៅការិយាល័យបោះឆ្នោត (បន្តសួរសំនួរលេខ ២) | ☐ | បានទៅការិយាល័យបោះឆ្នោត ប៉ុន្តែមិនបានបោះឆ្នោត (បន្តសួរសំនួរលេខ ៣) |

**២-មិនបានទៅការិយាល័យបោះឆ្នោតក្នុងឆ្នាំ ២០០៨ ដោយសារ មូលហេតុអ្វី?** (អាចជ្រើសរើសចំលើយលើសពីមួយ ហើយរំលងសំនួរលេខ ៣)

| | | | |
|---|---|---|---|
| ☐ | អត់ដឹង ឬគ្មានព័ត៌មានអំពីការបោះឆ្នោត | ☐ | ដោយសារតែចិត្តខ្ញុំមិនចង់ទៅបោះឆ្នោតតែម្តង ព្រោះអស់ទឹកចិត្ត ឬមិនចាប់អារម្មណ៍ |
| ☐ | ខ្ញុំនៅឆ្ងាយពីការិយាល័យបោះឆ្នោត | ☐ | មិនអាចដើរទៅបោះឆ្នោតបាន (ឈឺ ឬ ចាស់ពេក ឬពិការ) |
| ☐ | មិនបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត (គេប្រាប់ ឬ គិតថាមិនមានសិទ្ធិបោះឆ្នោត បើគ្មានប័ណ្ណព័ត៌មាននេះ) | ☐ | ខ្ញុំគិតថា ខ្ញុំគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ព្រោះខ្ញុំមិនបានទៅមើលឈ្មោះក្នុងកំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ ២០០៧ ឬមិនបានទៅចុះឈ្មោះបោះឆ្នោត |
| ☐ | កន្លែងធ្វើការមិនអនុញ្ញាតឱ្យខ្ញុំទៅបោះឆ្នោត | ☐ | រថយន្តឈ្នួលឡើងថ្លៃហួសហេតុពេក ខ្ញុំមិនចង់ចំណាយលុយដើម្បី ធ្វើដំណើរទៅ |
| ☐ | មូលហេតុផ្សេងៗ :________________________________ | | |

**៣-បានទៅការិយាល័យបោះឆ្នោតដែរ ប៉ុន្តែមិនបានបោះឆ្នោតព្រោះជួបឧបសគ្គ តើឧបសគ្គនោះជាអ្វីដែរ?** (អាចជ្រើសរើសចំលើយលើសពីមួយ)

| | | | |
|---|---|---|---|
| ☐ | មិនមានប័ណ្ណព័ត៌មានយកមកជាមួយ មន្ត្រីការិយាល័យឱ្យទៅយកវិញ ទើបបោះឆ្នោតបាន (តែគាត់ខ្ជិលមកវិញ) | ☐ | ការិយាល័យបោះឆ្នោតមានភាពចៀរចៃ, តម្រង់ជួរយូរពេកក៏ត្រឡប់ទៅផ្ទះវិញ |
| ☐ | មានអាជ្ញាធរ ឬ ភ្នាក់ងារគណបក្សនយោបាយ រារាំងមិនឱ្យចូល | ☐ | មានឯកសារគ្រប់គ្រាន់តែខុសទិន្នន័យ |
| ☐ | រកឈ្មោះ ឬការិយាល័យបោះឆ្នោតមិនឃើញព្រោះអត់ប័ណ្ណព័ត៌មាន | ☐ | បាត់ឯកសារបញ្ជាក់អត្តសញ្ញាណ |
| ☐ | រកឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬការិយាល័យមិនឃើញ ព្រោះគ្មានប័ណ្ណព័ត៌មាន តែធ្លាប់បានបោះឆ្នោតមុនៗដែរនៅក្នុងភូមិនេះ ដូចជាការបោះឆ្នោតឆ្នាំ ២០០៣ និង/ឬ ២០០៧ | | |
| ☐ | បានទៅដល់ខាងក្នុងការិយាល័យបោះឆ្នោត តែមន្ត្រីការិយាល័យប្រាប់ថា ឈ្មោះខ្លួនត្រូវបានបោះឆ្នោតរួចហើយ | | |
| ☐ | ហេតុផលផ្សេងពីនេះ សូមបញ្ជាក់ :________________________________ | | |

**៤-តើអ្នកបានប្រើឯកសារបញ្ជាក់អត្តសញ្ញាណប្រភេទណា (ដូចជាទម្រង់ ១០១៨ និងឯកសារផ្សេងទៀត) ដើម្បីបោះឆ្នោត នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៨ កន្លងទៅនេះ?** (អ្នកទៅសម្ភាសន៍ត្រូវបង្ហាញគំរូទម្រង់ ១០១៨)

☐ប្រើទំរង់ ១០១៨ (បន្តទៅសំនួរលេខ ៥) ☐ ប្រើឯកសារផ្សេងៗ (ជ្រើសរើសឯកសារណាមួយក្នុងតារាងខាងក្រោម *ហើយរំលងសំនួរលេខ ៥*)

| | | | |
|---|---|---|---|
| ☐ | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | ☐ | អត្តសញ្ញាណប័ណ្ណនគរបាលជាតិ |
| ☐ | លិខិតឆ្លងដែន | ☐ | អត្តសញ្ញាណប័ណ្ណកងយោធពលខេមរភូមិន្ទ |
| ☐ | សៀវភៅគ្រួសារមានរូបថតសាមីខ្លួន | ☐ | សុទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ |
| ☐ | ប័ណ្ណសំគាល់ខ្លួនចេញដោយក្រសួង ស្ថាប័នរដ្ឋ | ☐ | ឆាយាគណៈមហានិកាយ |
| ☐ | អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល | ☐ | សង្ឃដីកា |
| ☐ | ផ្សេងៗ សូមបញ្ជាក់: ____________ | | |

**៥-មូលហេតុអ្វី បានជាអ្នកប្រើទម្រង់ ១០១៨ នេះដើម្បីបោះឆ្នោត?**

| | | | |
|---|---|---|---|
| ☐ | គ្មានឯកសារបញ្ជាក់អត្តសញ្ញាណ | ☐ | កែតម្រូវព័ត៌មានឱ្យដូចបញ្ជីឈ្មោះបោះឆ្នោត |
| ☐ | ផ្សេងៗ សូមបញ្ជាក់: ____________ | | |

**៦- តើអ្នកគិតដូចម្តេចចំពោះការប្រើឯកសារបញ្ជាក់អត្តសញ្ញាណ ដើម្បីយកទៅបោះឆ្នោត សម្រាប់ការបោះឆ្នោតនៅពេលខាងមុខទៀត?**

*(ការបោះឆ្នោតឆ្នាំ ១៩៩៨ អ្នកបោះឆ្នោតយកតែប័ណ្ណបោះឆ្នោត ដែលមានលេខការិយាល័យស្រាប់ ប៉ុន្តែក្រោយមកចាប់ពីការបោះឆ្នោតឆ្នាំ ២០០៣ គេបានប្តូរឱ្យអ្នកបោះឆ្នោតយកឯកសារបញ្ជាក់អត្តសញ្ញាណ ដើម្បីជំនួសប័ណ្ណបោះឆ្នោតវិញ)*

☐គួរទុកដដែលដូចបច្ចុប្បន្ន ☐ធ្វើប័ណ្ណបោះឆ្នោតឱ្យច្បាស់ ដូចការបោះឆ្នោតឆ្នាំ ១៩៩៨ ☐មិនដឹង

☐យោបល់ផ្សេងៗ ____________

**៧-តើអ្នកបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កាលពីឆ្នាំ ២០០៧ ដែរឬទេ?**

☐ បានបោះឆ្នោត ☐ មិនបានបោះឆ្នោតទេ

**៨-នៅពេលបោះឆ្នោតឆ្នាំ ២០០៧ និង ២០០៨ កន្លងមក គេរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត លទ្ធផលបោះឆ្នោតបង្ហាញឱ្យដឹងថា ភូមិរបស់អ្នក បោះឆ្នោតគាំទ្រឱ្យគណបក្សណាមួយ តើអ្នកមានការព្រួយបារម្ភ ដែរឬទេ?**

☐ បារម្ភខ្លាំងណាស់ ☐ បារម្ភខ្លះដែរ ☐ មិនបារម្ភ ☐ មិនចាប់អារម្មណ៍

**៩-នៅពេលបោះឆ្នោតក្នុងឆ្នាំ ២០០៨ កន្លងមក តើអ្នក មិត្តភ័ក្រអ្នក គ្រួសារអ្នក ឬអ្នកជិតខាងអ្នក ធ្លាប់ជួបភាពមិនប្រក្រតី ដែរឬទេ?**

☐ ធ្លាប់ជួបភាពមិនប្រក្រតី (សួរបញ្ជាក់អំពីភាពមិនប្រក្រតីនោះជាអ្វី? ។ ចំលើយលើសពី១) ☐ មិនធ្លាប់ជួបភាពមិនប្រក្រតី ☐ មិនដឹង

| | | | | | |
|---|---|---|---|---|---|
| ☐ | ឱ្យអំណោយ ឬថវិកា ដោយបញ្ជាក់ថាបោះឆ្នោតឱ្យគណបក្សណាមួយ | ☐ | លុបឈ្មោះអ្នកបោះឆ្នោត | ☐ | បង្ខំឱ្យស្បថបោះឆ្នោតឱ្យគណបក្សណាមួយ |
| ☐ | ហឹង្សាប្រឆាំងអ្នកគាំទ្រ ឬ សកម្មជនគណបក្ស | ☐ | ប្រព័ន្ធផ្សព្វផ្សាយលំអៀង | ☐ | បន្លំសន្លឹកឆ្នោត |
| ☐ | គំរាមកំហែង | ☐ | គ្មានការសំងាត់ | | |
| ☐ | ផ្សេងៗ____________ | | | | |

**១០-តើអ្នកបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត កាលពីកំឡុងពេលបោះឆ្នោតឆ្នាំ ២០០៨ ដែរឬទេ?**

☐បានទទួល ☐មិនបានទទួល (មូលហេតុ ____________)

**១១-តើនៅភូមិ ឃុំអ្នករស់នៅមានការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត សំរាប់ការបោះឆ្នោតឆ្នាំ ២០០៨ កន្លងទៅនេះ ដែរឬទេ?**

☐ មាន ☐ មិនមាន (រំលងសំនួរលេខ ១២)

**១២-បើមាន តើអ្នកពេញចិត្តអំពីរបៀបនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះ ដែរឬទេ?**

☐ ពេញចិត្ត ☐ មិនពេញចិត្ត (សូមសួរបញ្ជាក់ តើគួរកែលំអរបែបណា?)

| | | | |
|---|---|---|---|
| ☐ | គ្រាន់តែពង្រឹងការងារធ្លាប់ធ្វើកន្លងមក ដែលមានមេភូមិ និង សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ទទួលខុសត្រូវ | ☐ | គ.ជ.ប តែមួយគត់ត្រូវទទួលខុសត្រូវ ហើយរៀបចំជ្រើសរើសមនុស្សឯករាជ្យរបស់ខ្លួន |
| ☐ | ផ្លាស់ប្តូររបៀបចែកឱ្យទៅសមាជិកគណបក្សនយោបាយ ទទួលខុសត្រូវវិញ | ☐ | ផ្សេងៗ________ |

**១៣- តើអ្នកយល់ថាមានការលំបាក ដែរឬទេ ដែលរៀបចំឱ្យអ្នកទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ជារៀងរាល់ឆ្នាំ?**

☐ មានការលំបាក ☐ គ្មានការលំបាក/ធម្មតា ☐ មិនដឹង

បើលំបាកមូលហេតុអ្វី? ________

**១៤-តើអ្នកគិតថាការចុះឈ្មោះ និងការធ្វើបញ្ជីឈ្មោះបោះឆ្នោត ចាំបាច់ធ្វើការផ្លាស់ប្តូរ ឬ កែលំអដែរឬទេ?**

☐ ចាំបាច់ (សូមសួរបញ្ជាក់ តើគួរផ្លាស់ប្តូរ ឬ កែលំអរបែបណា? ) ☐ មិនចាំបាច់ ☐ មិនដឹង

| | | | |
|---|---|---|---|
| ☐ | កែលំអលើបញ្ជីបោះឆ្នោតបច្ចុប្បន្ន | ☐ | ផ្លាស់ប្តូរបញ្ជីបោះឆ្នោតទាំងស្រុង មានន័យថាដូរប្រព័ន្ធចុះឈ្មោះបោះឆ្នោត |
| ☐ | ផ្សេងៗ________ | | |

**១៥-តើអ្នកមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែរឬទេ?**

☐ មាន ☐ មិនមាន

**១៦-សូមកត់ត្រាទិន្នន័យនៃអ្នកផ្តល់បទសម្ភាសន៍ ពីឯកសារប្រើពេលចុះ ឬបោះឆ្នោតក្នុងឆ្នាំ ២០០៨**

| ល.រ | ទិន្នន័យសំខាន់ៗ ដែលត្រូវស្រង់ | ទិន្នន័យពីក្នុងឯកសារសំគាល់អត្តសញ្ញាណអ្នកផ្តល់បទសម្ភាសន៍ ប្រើពេលចុះឈ្មោះ ឬបោះឆ្នោត (បំពេញដោយអ្នកសម្ភាសន៍) | | ទិន្នន័យពីក្នុងបញ្ជីឈ្មោះបោះឆ្នោតសម្រាប់ឆ្នាំ ២០០៩ (បំពេញដោយស្នាក់ការកណ្តាល) | | កូដៈ (បំពេញដោយស្នាក់ការកណ្តាល) ១=ដូចគ្នា ២=មិនដូចគ្នា ឬ មិនពេញលេញ ៣=គ្មានទិន្នន័យនៅក្នុងបញ្ជីអ្នកបោះឆ្នោត | | |
|---|---|---|---|---|---|---|---|---|
| ១៦-១ | ឈ្មោះ ❋ | នាមត្រកូលៈ | | នាមត្រកូលៈ | | 1 | 2 | 3 |
| | | នាមខ្លួនៈ | | នាមខ្លួនៈ | | | | |
| ១៦-២ | ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃៈ | | ថ្ងៃៈ | | 1 | 2 | 3 |
| | | ខែៈ | | ខែៈ | | | | |
| | | ឆ្នាំៈ | | ឆ្នាំៈ | | | | |
| ១៦-៣ | ភេទ | ប្រុស ☐ | ស្រី ☐ | ប្រុស ☐ | ស្រី ☐ | 1 | 2 | 3 |
| ១៦-៤ | អាសយដ្ឋាន | ភូមិៈ | | ភូមិៈ | | 1 | 2 | 3 |
| | | ឃុំៈ | | ឃុំៈ | | 1 | 2 | 3 |
| | | ខេត្តៈ | | ខេត្តៈ | | | | |

❋ **ខុមហ្វ្រែល** សន្យាថាប្រើប្រាស់ឈ្មោះរបស់អ្នកផ្តល់ចំលើយសម្រាប់តែផ្ទៀងផ្ទាត់ ជាមួយបញ្ជីឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ មិនបង្ហាញដល់អ្នកដទៃទៀតទេ។

**១៧-តើអ្នកផ្តល់បទសម្ភាសន៍ មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត សំរាប់ឆ្នាំ ២០០៩ ដែរឬទេ?** (បំពេញដោយស្នាក់ការកណ្តាល)

☐ មាន ☐ មិនមាន

**១៨-បើមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតសម្រាប់ឆ្នាំ ២០០៩ តើមានលេខរៀងទីប៉ុន្មាន?** (បំពេញដោយស្នាក់ការកណ្តាល)

មានលេខរៀងទី : ________

# ឧបសម្ព័ន្ធ ៣: ការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោតជាមួយបញ្ជីបោះឆ្នោតឆ្នាំ ២០០៨

## តារាងទី ១២: ការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោត (ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត) ក្នុងបញ្ជីបោះឆ្នោត ២០០៨

| ល.រ | ខេត្ត | ត្រឹមត្រូវ | | មិនត្រឹមត្រូវ | | គ្មានទិន្នន័យ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១ | បន្ទាយមានជ័យ | ២០៨ | ៥៥,០៣ | ៦១ | ១៦,១៤ | ១០៩ | ២៨,៨៤ |
| ២ | បាត់ដំបង | ២៨៨ | ៧៥,៥៩ | ៥២ | ១៣,៦៥ | ៤១ | ១០,៧៦ |
| ៣ | កំពង់ចាម | ២២៧ | ៦០,៣៧ | ៦៩ | ១៨,៣៥ | ៨០ | ២១,២៨ |
| ៤ | កំពង់ឆ្នាំង | ២៦៨ | ៧១,២៨ | ៤៣ | ១១,៤៤ | ៦៥ | ១៧,២៩ |
| ៥ | កំពង់ស្ពឺ | ២៥៨ | ៦៧,៨៩ | ៦២ | ១៦,៣២ | ៦០ | ១៥,៧៩ |
| ៦ | កំពង់ធំ | ២៦៨ | ៧១,០៩ | ៦៦ | ១៧,៥១ | ៤៣ | ១១,៤១ |
| ៧ | កំពត | ២៣៤ | ៦២,០៧ | ៨៨ | ២៣,៣៤ | ៥៥ | ១៤,៥៩ |
| ៨ | កណ្តាល | ២៣៧ | ៦៤,៤០ | ៧៩ | ២១,៤៧ | ៥២ | ១៤,១៣ |
| ៩ | កោះកុង | ២៥៥ | ៧៤,១៣ | ៤៧ | ១៣,៦៦ | ៤២ | ១២,២១ |
| ១០ | ក្រចេះ | ២៦៥ | ៧១,៦២ | ៥៣ | ១៤,៣២ | ៥២ | ១៤,០៥ |
| ១១ | មណ្ឌលគិរី | ១៤៨ | ៤៧,៤៤ | ៦៤ | ២០,៥១ | ១០០ | ៣២,០៥ |
| ១២ | ភ្នំពេញ | ២៥៣ | ៦៦,៧៥ | ៤០ | ១០,៥៥ | ៨៦ | ២២,៦៩ |
| ១៣ | ព្រះវិហារ | ១៨៩ | ៥៤,១៥ | ១០២ | ២៩,២៣ | ៥៨ | ១៦,៦២ |
| ១៤ | ព្រៃវែង | ២០៥ | ៥៣,៨១ | ៨២ | ២១,៥២ | ៩៤ | ២៤,៦៧ |
| ១៥ | ពោធិសាត់ | ២៧០ | ៧២,៧៨ | ៥១ | ១៣,៧៥ | ៥០ | ១៣,៤៨ |
| ១៦ | រតនគិរី | ១២៩ | ៣៧,០៧ | ៨១ | ២៣,២៨ | ១៣៨ | ៣៩,៦៦ |
| ១៧ | សៀមរាប | ២២៦ | ៥៩,៦៣ | ៨០ | ២១,១១ | ៧៣ | ១៩,២៦ |
| ១៨ | ក្រុងព្រះសីហនុ | ២២២ | ៦២,០១ | ៦២ | ១៧,៣២ | ៧៤ | ២០,៦៧ |
| ១៩ | ស្ទឹងត្រែង | ២៣៩ | ៧០,០៩ | ៦១ | ១៧,៨៩ | ៤១ | ១២,០២ |
| ២០ | ស្វាយរៀង | ២៦១ | ៦៩,៤១ | ៨៧ | ២៣,១៤ | ២៨ | ៧,៤៥ |
| ២១ | តាកែវ | ២៥៦ | ៦៧,១៩ | ៦៦ | ១៧,៣២ | ៥៩ | ១៥,៤៩ |
| ២២ | ឧត្តរមានជ័យ | ១៦៤ | ៤៦,០៧ | ៧៣ | ២០,៥១ | ១១៩ | ៣៣,៤៣ |
| ២៣ | កែប | ២១៤ | ៧២,៧៩ | ៥៦ | ១៩,០៥ | ២៤ | ៨,១៦ |
| ២៤ | ប៉ៃលិន | ២១៧ | ៦៨,៤៥ | ៤៣ | ១៣,៥៦ | ៥៧ | ១៧,៩៨ |
| **សរុប** | | **៥.៥០១** | **៦៣,៤៦** | **១.៥៦៨** | **១៨,០៩** | **១.៦០០** | **១៨,៤៦** |

## តារាង ១៣: ការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោត (ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន) ក្នុងបញ្ជីបោះឆ្នោត ២០០៨

| ល.រ | ខេត្ត | ត្រឹមត្រូវ | | មិនត្រឹមត្រូវ | | គ្មានទិន្នន័យ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១ | បន្ទាយមានជ័យ | ១៩៣ | ៥១,០៦ | ៧៦ | ២០,១១ | ១០៩ | ២៨,៨៤ |
| ២ | បាត់ដំបង | ២៦១ | ៦៨,៥០ | ៧៩ | ២០,៧៣ | ៤១ | ១០,៧៦ |
| ៣ | កំពង់ចាម | ២២២ | ៥៩,០៤ | ៧៤ | ១៩,៦៨ | ៨០ | ២១,២៨ |
| ៤ | កំពង់ឆ្នាំង | ២៦៧ | ៧១,០១ | ៤៤ | ១១,៧០ | ៦៥ | ១៧,២៩ |
| ៥ | កំពង់ស្ពឺ | ២៤៨ | ៦៥,២៦ | ៧១ | ១៨,៦៨ | ៦១ | ១៦,០៥ |
| ៦ | កំពង់ធំ | ២៦៥ | ៧០,២៩ | ៦៩ | ១៨,៣០ | ៤៣ | ១១,៤១ |
| ៧ | កំពត | ២២៧ | ៦០,២១ | ៩៥ | ២៥,២០ | ៥៥ | ១៤,៥៩ |
| ៨ | កណ្តាល | ២៣៣ | ៦៣,៣២ | ៨៣ | ២២,៥៥ | ៥២ | ១៤,១៣ |
| ៩ | កោះកុង | ២០២ | ៥៨,៧២ | ១០០ | ២៩,០៧ | ៤២ | ១២,២១ |
| ១០ | ក្រចេះ | ២៦៣ | ៧១,០៨ | ៥៥ | ១៤,៨៦ | ៥២ | ១៤,០៥ |
| ១១ | មណ្ឌលគិរី | ១១១ | ៣៥,៥៨ | ១០១ | ៣២,៣៧ | ១០០ | ៣២,០៥ |
| ១២ | ភ្នំពេញ | ២៣៧ | ៦២,៥៣ | ៥២ | ១៣,៧២ | ៩០ | ២៣,៧៥ |
| ១៣ | ព្រះវិហារ | ១៥៨ | ៤៥,២៧ | ១៣៣ | ៣៨,១១ | ៥៨ | ១៦,៦២ |
| ១៤ | ព្រៃវែង | ២០៤ | ៥៣,៥៤ | ៨៣ | ២១,៧៨ | ៩៤ | ២៤,៦៧ |
| ១៥ | ពោធិសាត់ | ២៥១ | ៦៧,៦៥ | ៧០ | ១៨,៨៧ | ៥០ | ១៣,៤៨ |
| ១៦ | រតនគិរី | ១២៩ | ៣៧,០៧ | ៨១ | ២៣,២៨ | ១៣៨ | ៣៩,៦៦ |
| ១៧ | សៀមរាប | ២១៨ | ៥៧,៥២ | ៨៨ | ២៣,២២ | ៧៣ | ១៩,២៦ |
| ១៨ | ក្រុងព្រះសីហនុ | ១៧២ | ៤៨,០៤ | ១១២ | ៣១,២៨ | ៧៤ | ២០,៦៧ |
| ១៩ | ស្ទឹងត្រែង | ២៣៩ | ៧០,០៩ | ៦១ | ១៧,៨៩ | ៤១ | ១២,០២ |
| ២០ | ស្វាយរៀង | ២៥៧ | ៦៨,៣៥ | ៩១ | ២៤,២០ | ២៨ | ៧,៤៥ |
| ២១ | តាកែវ | ២៥៦ | ៦៧,១៩ | ៦៦ | ១៧,៣២ | ៥៩ | ១៥,៤៩ |
| ២២ | ឧត្តរមានជ័យ | ១៥៦ | ៤៣,៨២ | ៨១ | ២២,៧៥ | ១១៩ | ៣៣,៤៣ |
| ២៣ | កែប | ២០៣ | ៦៩,០៥ | ៦៧ | ២២,៧៩ | ២៤ | ៨,១៦ |
| ២៤ | ប៉ៃលិន | ២០០ | ៦៣,០៩ | ៦០ | ១៨,៩៣ | ៥៧ | ១៧,៩៨ |
| **សរុប** | | **៥.១៧២** | **៥៩.៦៦** | **១.៨៩២** | **២១.៨២** | **១.៦០៥** | **១៨,៥១** |

## តារាង ១៤: ការផ្ទៀងផ្ទាត់ "ឈ្មោះ" អ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ២០០៨

| ល.រ | ខេត្ត | ត្រឹមត្រូវ | | មិនត្រឹមត្រូវ | | គ្មានទិន្នន័យ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១ | បន្ទាយមានជ័យ | ២៤៧ | ៦៦,០៤ | ១៨ | ៤,៨១ | ១០៩ | ២៩,១៤ |
| ២ | បាត់ដំបង | ២៩១ | ៨៤,៥៩ | ១៣ | ៣,៧៨ | ៤០ | ១១,៦៣ |
| ៣ | កំពង់ចាម | ២៦៥ | ៧២,២១ | ២២ | ៥,៩៥ | ៨០ | ២១,៨០ |
| ៤ | កំពង់ឆ្នាំង | ២៨៧ | ៨០,១៧ | ៦ | ១,៦៨ | ៦៥ | ១៨,១៦ |
| ៥ | កំពង់ស្ពឺ | ២៥៦ | ៧៦,១៩ | ២០ | ៥,៩៥ | ៦០ | ១៧,៨៦ |
| ៦ | កំពង់ធំ | ២៥៥ | ៧៩,៤៤ | ២៣ | ៧,១៧ | ៤៣ | ១៣,៤០ |
| ៧ | កំពត | ២៦៧ | ៧៦,៩៥ | ២៥ | ៧,២០ | ៥៥ | ១៥,៨៥ |
| ៨ | កណ្តាល | ២៧៤ | ៧៦,៩៧ | ៣០ | ៨,៤៣ | ៥២ | ១៤,៦១ |
| ៩ | កោះកុង | ២៥២ | ៨០,៧៧ | ១៨ | ៥,៧៧ | ៤២ | ១៣,៤៦ |
| ១០ | ក្រចេះ | ២៨៦ | ៨០,១១ | ១៩ | ៥,៣២ | ៥២ | ១៤,៥៧ |
| ១១ | មណ្ឌលគិរី | ១៥១ | ៥១,៧១ | ៤១ | ១៤,០៤ | ១០០ | ៣៤,២៥ |
| ១២ | ភ្នំពេញ | ២០៧ | ៦៨,៥៤ | ៩ | ២,៩៨ | ៨៦ | ២៨,៤៨ |
| ១៣ | ព្រះវិហារ | ២៦១ | ៧៥,៨៧ | ២៥ | ៧,២៧ | ៥៨ | ១៦,៨៦ |
| ១៤ | ព្រៃវែង | ២៥០ | ៦៧,៧៥ | ២៦ | ៧,០៥ | ៩៣ | ២៥,២០ |
| ១៥ | ពោធិសាត់ | ២៧៣ | ៨០,៥៣ | ១៦ | ៤,៧២ | ៥០ | ១៤,៧៥ |
| ១៦ | រតនគិរី | ១៦២ | ៤៩,០៩ | ៣០ | ៩,០៩ | ១៣៨ | ៤១,៨២ |
| ១៧ | សៀមរាប | ២៦៧ | ៧៣,៥៥ | ២៣ | ៦,៣៤ | ៧៣ | ២០,១១ |
| ១៨ | ក្រុងព្រះសីហនុ | ១៤៤ | ៥៩,០២ | ២៧ | ១១,០៧ | ៧៣ | ២៩,៩២ |
| ១៩ | ស្ទឹងត្រែង | ២៦៦ | ៧៨,២៤ | ៣៣ | ៩,៧១ | ៤១ | ១២,០៦ |
| ២០ | ស្វាយរៀង | ២៨៣ | ៧៩,៤៩ | ៤៥ | ១២,៦៤ | ២៨ | ៧,៨៧ |
| ២១ | តាកែវ | ២៨១ | ៧៥,១៣ | ៣៤ | ៩,០៩ | ៥៩ | ១៥,៧៨ |
| ២២ | ឧត្តរមានជ័យ | ២១០ | ៥៩,១៥ | ២៦ | ៧,៣២ | ១១៩ | ៣៣,៥២ |
| ២៣ | កែប | ២២៧ | ៨០,៥០ | ៣១ | ១០,៩៩ | ២៤ | ៨,៥១ |
| ២៤ | ប៉ៃលិន | ២៣៩ | ៧៥,៦៣ | ២០ | ៦,៣៣ | ៥៧ | ១៨,០៤ |
| **សរុប** | | **៥.៩០១** | **៧៣,០៥** | **៥៨០** | **៧,១៨** | **១.៥៩៧** | **១៩,៧៧** |

## តារាង ១៥: ការផ្ទៀងផ្ទាត់ "ថ្ងៃខែឆ្នាំកំណើត" ក្នុងបញ្ជីបោះឆ្នោត ២០០៨

| ល.រ | ខេត្ត | ត្រឹមត្រូវ | | មិនត្រឹមត្រូវ | | គ្មានទិន្នន័យ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១ | បន្ទាយមានជ័យ | ២១៩ | ៥៨,៥៦ | ៤៦ | ១២,៣០ | ១០៩ | ២៩,១៤ |
| ២ | បាត់ដំបង | ២៦៣ | ៧៦,២៣ | ៤១ | ១១,៨៨ | ៤១ | ១១,៨៨ |
| ៣ | កំពង់ចាម | ២៣១ | ៦២,៩៤ | ៥៦ | ១៥,២៦ | ៨០ | ២១,៨០ |
| ៤ | កំពង់ឆ្នាំង | ២៥៦ | ៧១,៧១ | ៣៧ | ១០,៣៦ | ៦៤ | ១៧,៩៣ |
| ៥ | កំពង់ស្ពឺ | ២៣១ | ៦៨,៧៥ | ៤៥ | ១៣,៣៩ | ៦០ | ១៧,៨៦ |
| ៦ | កំពង់ធំ | ២២៨ | ៧១,២៥ | ៤៩ | ១៥,៣១ | ៤៣ | ១៣,៤៤ |
| ៧ | កំពត | ២២២ | ៦៣,៩៨ | ៧០ | ២០,១៧ | ៥៥ | ១៥,៨៥ |
| ៨ | កណ្តាល | ២៥២ | ៧០,៧៩ | ៥២ | ១៤,៦១ | ៥២ | ១៤,៦១ |
| ៩ | កោះកុង | ២៣៧ | ៧៥,៩៦ | ៣៣ | ១០,៥៨ | ៤២ | ១៣,៤៦ |
| ១០ | ក្រចេះ | ២៦៧ | ៧៤,៧៩ | ៣៨ | ១០,៦៤ | ៥២ | ១៤,៥៧ |
| ១១ | មណ្ឌលគិរី | ១៥៩ | ៥៤,៤៥ | ៣៣ | ១១,៣០ | ១០០ | ៣៤,២៥ |
| ១២ | ភ្នំពេញ | ១៨៤ | ៦០,៩៣ | ៣២ | ១០,៦០ | ៨៦ | ២៨,៤៨ |
| ១៣ | ព្រះវិហារ | ១៩៣ | ៥៦,១០ | ៩៣ | ២៧,០៣ | ៥៨ | ១៦,៨៦ |
| ១៤ | ព្រៃវែង | ២១០ | ៥៦,៩១ | ៦៦ | ១៧,៨៩ | ៩៣ | ២៥,២០ |
| ១៥ | ពោធិសាត់ | ២៥១ | ៧៤,០៤ | ៣៨ | ១១,២១ | ៥០ | ១៤,៧៥ |
| ១៦ | រតនគិរី | ១៣៥ | ៤១,០៣ | ៥៦ | ១៧,០២ | ១៣៨ | ៤១,៩៥ |
| ១៧ | សៀមរាប | ២២៦ | ៦២,២៦ | ៦៤ | ១៧,៦៣ | ៧៣ | ២០,១១ |
| ១៨ | ក្រុងព្រះសីហនុ | ១៣០ | ៥៣,២៨ | ៤០ | ១៦,៣៩ | ៧៤ | ៣០,៣៣ |
| ១៩ | ស្ទឹងត្រែង | ២៦៩ | ៧៩,១២ | ៣០ | ៨,៨២ | ៤១ | ១២,០៦ |
| ២០ | ស្វាយរៀង | ២៧៨ | ៧៨,០៩ | ៥០ | ១៤,០៤ | ២៨ | ៧,៨៧ |
| ២១ | តាកែវ | ២៨១ | ៧៥,១៣ | ៣៤ | ៩,០៩ | ៥៩ | ១៥,៧៨ |
| ២២ | ឧត្តរមានជ័យ | ១៨០ | ៥០,៧០ | ៥៦ | ១៥,៧៧ | ១១៩ | ៣៣,៥២ |
| ២៣ | កែប | ២២៥ | ៧៩,៧៩ | ៣៣ | ១១,៧០ | ២៤ | ៨,៥១ |
| ២៤ | ប៉ៃលិន | ២៣៤ | ៧៤,០៥ | ២៥ | ៧,៩១ | ៥៧ | ១៨,០៤ |
| **សរុប** | | **៥.៣៦១** | **៦៦,៣៨** | **១.១១៧** | **១៣,៨៣** | **១.៥៩៨** | **១៩,៧៩** |

## តារាង ១៦: ការផ្ទៀងផ្ទាត់ "ភេទ" អ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ២០០៨

| ល.រ | ខេត្ត | ត្រឹមត្រូវ | | មិនត្រឹមត្រូវ | | គ្មានទិន្នន័យ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១ | បន្ទាយមានជ័យ | ២៦២ | ៧០,២៤ | ២ | ០,៥៤ | ១០៩ | ២៩,២២ |
| ២ | បាត់ដំបង | ៣០៤ | ៨៨,១២ | ០ | ០,០០ | ៤១ | ១១,៨៨ |
| ៣ | កំពង់ចាម | ២៨៦ | ៧៧,៩៣ | ១ | ០,២៧ | ៨០ | ២១,៨០ |
| ៤ | កំពង់ឆ្នាំង | ២៩២ | ៨២,០២ | ១ | ០,២៨ | ៦៣ | ១៧,៧០ |
| ៥ | កំពង់ស្ពឺ | ២៧៤ | ៨១,៥៥ | ២ | ០,៦០ | ៦០ | ១៧,៨៦ |
| ៦ | កំពង់ធំ | ២៧៥ | ៨៥,៩៤ | ២ | ០,៦៣ | ៤៣ | ១៣,៤៤ |
| ៧ | កំពត | ២៩០ | ៨៣,៥៧ | ២ | ០,៥៨ | ៥៥ | ១៥,៨៥ |
| ៨ | កណ្ដាល | ៣០៤ | ៨៥,៣៩ | ០ | ០,០០ | ៥២ | ១៤,៦១ |
| ៩ | កោះកុង | ២៧០ | ៨៦,៥៤ | ០ | ០,០០ | ៤២ | ១៣,៤៦ |
| ១០ | ក្រចេះ | ៣០៥ | ៨៥,៤៣ | ០ | ០,០០ | ៥២ | ១៤,៥៧ |
| ១១ | មណ្ឌលគិរី | ១៩០ | ៦៥,០៧ | ២ | ០,៦៨ | ១០០ | ៣៤,២៥ |
| ១២ | ភ្នំពេញ | ២១៥ | ៧១,១៩ | ១ | ០,៣៣ | ៨៦ | ២៨,៤៨ |
| ១៣ | ព្រះវិហារ | ២៨៦ | ៨៣,១៤ | ០ | ០,០០ | ៥៨ | ១៦,៨៦ |
| ១៤ | ព្រៃវែង | ២៧៤ | ៧៤,២៥ | ១ | ០,២៧ | ៩៤ | ២៥,៤៧ |
| ១៥ | ពោធិសាត់ | ២៨៧ | ៨៤,៦៦ | ២ | ០,៥៩ | ៥០ | ១៤,៧៥ |
| ១៦ | រតនគិរី | ១៩០ | ៥៧,៥៨ | ៣ | ០,៩១ | ១៣៧ | ៤១,៥២ |
| ១៧ | សៀមរាប | ២៩០ | ៧៩,៨៩ | ០ | ០,០០ | ៧៣ | ២០,១១ |
| ១៨ | ក្រុងព្រះសីហនុ | ១៦៨ | ៦៨,៨៥ | ៣ | ១,២៣ | ៧៣ | ២៩,៩២ |
| ១៩ | ស្ទឹងត្រែង | ២៩៧ | ៨៧,៣៥ | ២ | ០,៥៩ | ៤១ | ១២,០៦ |
| ២០ | ស្វាយរៀង | ៣២៥ | ៩១,២៩ | ៣ | ០,៨៤ | ២៨ | ៧,៨៧ |
| ២១ | តាកែវ | ៣១៣ | ៨៣,៦៩ | ២ | ០,៥៣ | ៥៩ | ១៥,៧៨ |
| ២២ | ឧត្ដរមានជ័យ | ២៣៥ | ៦៦,២០ | ១ | ០,២៨ | ១១៩ | ៣៣,៥២ |
| ២៣ | កែប | ២៥៧ | ៩១,១៣ | ១ | ០,៣៥ | ២៤ | ៨,៥១ |
| ២៤ | ប៉ៃលិន | ២៥៩ | ៨១,៩៦ | ០ | ០,០០ | ៥៧ | ១៨,០៤ |
| **សរុប** | | **៦.៤៤៨** | **៧៩.៨៥** | **៣១** | **០.៣៨** | **១.៥៩៦** | **១៩.៧៦** |

## តារាង ១៧: ការផ្ទៀងផ្ទាត់ "អាសយដ្ឋាន" (ឃុំ និងខេត្ត) អ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ២០០៨

| ល.រ | ខេត្ត | ត្រឹមត្រូវ | | មិនត្រឹមត្រូវ | | គ្មានទិន្នន័យ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១ | បន្ទាយមានជ័យ | ២៤៧ | ៦៦,២២ | ១៨ | ៤,៨៣ | ១០៨ | ២៨,៩៥ |
| ២ | បាត់ដំបង | ២៧១ | ៧៨,៥៥ | ៣៣ | ៩,៥៧ | ៤១ | ១១,៨៨ |
| ៣ | កំពង់ចាម | ២៧៩ | ៧៦,០២ | ៨ | ២,១៨ | ៨០ | ២១,៨០ |
| ៤ | កំពង់ឆ្នាំង | ២៩២ | ៨១,៧៩ | ១ | ០,២៨ | ៦៤ | ១៧,៩៣ |
| ៥ | កំពង់ស្ពឺ | ២៦១ | ៧៧,៦៨ | ១៤ | ៤,១៧ | ៦១ | ១៨,១៥ |
| ៦ | កំពង់ធំ | ២៦៩ | ៨៤,០៦ | ៨ | ២,៥០ | ៤៣ | ១៣,៤៤ |
| ៧ | កំពត | ២៨២ | ៨១,៥០ | ៩ | ២,៦០ | ៥៥ | ១៥,៩០ |
| ៨ | កណ្ដាល | ២៩៨ | ៨៣,៧១ | ៦ | ១,៦៩ | ៥២ | ១៤,៦១ |
| ៩ | កោះកុង | ២០៧ | ៦៦,៣៥ | ៦៣ | ២០,១៩ | ៤២ | ១៣,៤៦ |
| ១០ | ក្រចេះ | ៣០២ | ៨៤,៥៩ | ៣ | ០,៨៤ | ៥២ | ១៤,៥៧ |
| ១១ | មណ្ឌលគីរី | ១៣៣ | ៤៥,៨៦ | ៥៧ | ១៩,៦៦ | ១០០ | ៣៤,៤៨ |
| ១២ | ភ្នំពេញ | ១៩៤ | ៦៤,៨៨ | ១៥ | ៥,០២ | ៩០ | ៣០,១០ |
| ១៣ | ព្រះវិហារ | ២៣៥ | ៦៨,៣១ | ៥១ | ១៤,៨៣ | ៥៨ | ១៦,៨៦ |
| ១៤ | ព្រៃវែង | ២៧៤ | ៧៤,២៥ | ២ | ០,៥៤ | ៩៣ | ២៥,២០ |
| ១៥ | ពោធិសាត់ | ២៦៥ | ៧៨,១៧ | ២៤ | ៧,០៨ | ៥០ | ១៤,៧៥ |
| ១៦ | រតនគីរី | ១៨៥ | ៥៦,០៦ | ៧ | ២,១២ | ១៣៨ | ៤១,៨២ |
| ១៧ | សៀមរាប | ២៨១ | ៧៧,៤១ | ៩ | ២,៤៨ | ៧៣ | ២០,១១ |
| ១៨ | ក្រុងព្រះសីហនុ | ៩៩ | ៤០,៥៧ | ៧២ | ២៩,៥១ | ៧៣ | ២៩,៩២ |
| ១៩ | ស្ទឹងត្រែង | ២៩៧ | ៨៧,៣៥ | ២ | ០,៥៩ | ៤១ | ១២,០៦ |
| ២០ | ស្វាយរៀង | ៣២៤ | ៩១,០១ | ៤ | ១,១២ | ២៨ | ៧,៨៧ |
| ២១ | តាកែវ | ៣១៥ | ៨៤,២២ | ០ | ០,០០ | ៥៩ | ១៥,៧៨ |
| ២២ | ឧត្ដរមានជ័យ | ២២២ | ៦២,៥៤ | ១៤ | ៣,៩៤ | ១១៩ | ៣៣,៥២ |
| ២៣ | កែប | ២៤៥ | ៨៦,៨៨ | ១៣ | ៤,៦១ | ២៤ | ៨,៥១ |
| ២៤ | ប៉ៃលិន | ២៤១ | ៧៦,២៧ | ១៨ | ៥,៧០ | ៥៧ | ១៨,០៤ |
| **សរុប** | | **៦.០១៨** | **៧៤.៥៧** | **៤៥១** | **៥.៥៩** | **១.៦០១** | **១៩.៨៤** |

# ឧបសម្ព័ន្ធ ៤: រូបភាពសកម្មភាពការងារ



ការជួបធ្វើសវនាការ ជាមួយគណបក្សនយោបាយ ស្តីពី "ការស្រាវជ្រាវបញ្ជីបោះឆ្នោត និងការចុះឈ្មោះអ្នកបោះឆ្នោត" នៅក្នុងខែ មករា ២០០៩




វគ្គបណ្តុះបណ្តាល ស្តីពី "ការស្រាវជ្រាវបញ្ជីបោះឆ្នោត និងការចុះឈ្មោះអ្នកបោះឆ្នោត" នៅខេត្តសៀមរាប ថ្ងៃទី ២-៣ ខែ មេសា ២០០៩



វគ្គបណ្តុះបណ្តាល ស្តីពី "ការស្រាវជ្រាវបញ្ជី បោះឆ្នោត និងការចុះឈ្មោះអ្នកបោះឆ្នោត" នៅខេត្តបាត់ដំបង ថ្ងៃទី ២៧ កុម្ភៈ ២០០៩



ការសាកសួរព័ត៌មាន ជាមួយលោកប្រធានភូមិ ដើម្បីធ្វើបទសម្ភាសន៍ ជាមួយប្រជាពលរដ្ឋក្នុង ភូមិសណ្តាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្ត សៀមរាប ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០០៩

សកម្មភាពធ្វើការបែងចែកក្រុមការងារ ដើម្បីធ្វើបទសម្ភាសន៍ ជាមួយប្រជាពលរដ្ឋ ក្នុងភូមិសណ្តាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០០៩





សកម្មភាពណែនាំសិក្ខាកាម ស្តីពីការចាប់ឆ្នោត ជ្រើសរើសខ្នងផ្ទះ ក្នុងភូមិសណ្តាន់ សង្កាត់ ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០០៩។



សកម្មភាពរបស់សិក្ខាកាម នៅខេត្តសៀមរាប ពេលអនុវត្តការសម្ភាសន៍សាកល្បង ក្នុងភូមិសណ្ដាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប ថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០០៩។



សកម្មភាពរបស់សិក្ខាកាម នៅខេត្តឧត្តរមានជ័យ ពេលអនុវត្តការសម្ភាសន៍សាកល្បង ក្នុងភូមិសណ្ដាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប ថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០០៩។



សកម្មភាពរបស់សិក្ខាកាម ពេលអនុវត្ត ការសម្ភាសន៍សាកល្បង នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ ក្នុងភូមិភូមិ១ ឃុំកាចាញ ស្រុកបានលុង ខេត្តរតនគិរី។



សកម្មភាពក្រុមការងារបញ្ចូលទិន្នន័យ ទៅក្នុងម៉ាស៊ីនកុំព្យូទ័រ ពីថ្ងៃទី ១៧ ដល់ ២៦ ខែ មីនា ឆ្នាំ២០០៩។



ការប្រជុំ ពិភាក្សា និងបង្ហាញនូវលទ្ធផល ដែលបានរកឃើញ រវាងគណៈកម្មការនាយក ខុមហ្វ្រែល និងក្រុមការងារ ដើម្បីជជែករកអនុសាសន៍ នៅឯស្នាក់ការកណ្តាល នៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០០៩។



កិច្ចប្រជុំពិភាក្សា ផ្តល់អនុសាសន៍ ចំពោះលទ្ធផលដែលបានរកឃើញ ជាមួយ UNDP, ForumSyd, NDI, EU advisor to NEC, គណៈកម្មាធិការនាយក ខុមហ្វ្រែល និងក្រុមការងារគ្រូបង្គោល នៅឯសណ្ឋាគារអ៊ីមភើរៀល ថ្ងៃទី ២២ មេសា ២០០៩។ The



កិច្ចប្រជុំ ជជែកពិភាក្សា និងផ្តល់អនុសាសន៍លើលទ្ធផល ដែលបានរកឃើញ ជាមួយតំណាងអ្នកផ្តល់ជំនួយពី ស្ថានទូតអង់គ្លេស ។



សកម្មភាពតំណាងក្រុមការងារស្រាវជ្រាវ បង្ហាញនូវលទ្ធផល និងអនុសាសន៍ ដែលបានរកឃើញ ជូនដល់អ្នកតំណាងឱ្យក្រសួងមហាផ្ទៃ នៅឯសាលប្រជុំ ក្នុងថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៩។



សកម្មភាពតំណាងក្រុមការងារស្រាវជ្រាវ បង្ហាញនូវលទ្ធផល និងអនុសាសន៍ ដែលបានរកឃើញ ជូនដល់អ្នក តំណាងឱ្យស្ថាប័ន គ.ជ.ប នៅឯសាលប្រជុំ ក្នុងថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៩។